ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០២៥

នៅក្នុងឆមាសទី១នៃឆ្នាំ២០២៥នេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

## I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥

### ១-មុខងារនីតិកម្ម

- បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងារនីតិកម្ម៖

❖ កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៥ **ចំនួន៧លើក** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដើម្បី៖

១- ពិនិត្យ និងសម្រេចលើសេចក្តីព្រាងវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា។

២- ពិនិត្យ និងសម្រេចលើសេចក្តីព្រាងច្បាប់ ចំនួន៣ច្បាប់។

៣- ពិនិត្យ និងសម្រេចលើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យបណ្តាក្រុមហ៊ុនវិនិយោគអភិវឌ្ឍន៍ថាមពលអគ្គិសនី ចំនួន២៤ច្បាប់។

៤- ពិនិត្យ និងសម្រេចលើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ របស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា។

៥- ពិនិត្យ និងសម្រេចលើរបាយការណ៍សង្ខេបស្តីពី សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី២ និងលើកទី៣ នីតិកាលទី៥។

៦- ពិនិត្យ និងសម្រេចលើសំណើរបស់គណបក្សប្រជាជនកម្ពុជាលេខ ០០៩/០៥២៥/លគ.គក ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៥ និងលេខ ០១១/០៥២៥/លគ.គក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៥ និង

៧- ពិនិត្យ និងសម្រេចលើការបោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការមហាផ្ទៃ ការពារជាតិ មុខងារសាធារណៈ និងកិច្ចការព្រំដែន និងគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី៣ព្រឹទ្ធសភា នីតិកាលទី៥។

❖ សម័យប្រជុំពេញអង្គ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ **ចំនួន៥លើក** ក្រោមអធិបតីភាព ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដែលមាន របៀបវារៈ ដូចខាងក្រោម៖

១- ពិនិត្យ និងអនុម័តលើសេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា។

២- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ របស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា។

៣- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការប្រឆាំងការមិនទទួលស្គាល់ ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

៤- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការចាត់ចែងជាបណ្តោះអាសន្ននូវ វត្ថុចាប់យក។

៥- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ដលផល។

៦- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានា ទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន បានយ៉ាន អេនើជី ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនី ដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព៣០០មេហ្គាវ៉ាត់ នៅខេត្តកំពង់ឆ្នាំង។

៧- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានា ទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន វេ សាន់ ស៊ី.អេ.ភី យូណាយធីត អ៊ិនវេសម៉ិន ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនី ដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព១០០មេហ្គាវ៉ាត់ នៅខេត្តបាត់ដំបង។

៨- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានា ទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ផេល ប្លូ ជត ឌីវេឡុបម៉ិន ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនី ដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព១២០មេហ្គាវ៉ាត់ នៅខេត្តព្រៃវែង។

៩- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានា ទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន អេនើរើស ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនី ដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព៣៥០មេហ្គាវ៉ាត់ នៅខេត្តពោធិ៍សាត់។

១០- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានា ទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន រីស៊ីលាន មិវ៉ាយ ឯ.ក

សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនី ដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព១០០មេហ្គាវ៉ាត់ នៅខេត្តពោធិ៍សាត់។

១១- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន សិនកៃ គីរី អ៊ិនវេសមិន ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនី ដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព១០០មេហ្គាវ៉ាត់ នៅខេត្តព្រះសីហនុ។

១២- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន តាំង ឡៃស៊ុ អ៊ីមផត អិចផត សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនី ដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព៣០មេហ្គាវ៉ាត់ នៅខេត្តពោធិ៍សាត់។

១៣- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន រ៉ូយ៉ាល់ គ្រុប ផៅវ៉ែខូ អិលធីឌី សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនី ដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព២០០មេហ្គាវ៉ាត់ នៅខេត្តស្ទឹងត្រែង។

១៤- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ឆេមពាន គ្រុប ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនី ដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព៥០មេហ្គាវ៉ាត់ នៅខេត្តពោធិ៍សាត់។

១៥- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការជានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ប៊ីលហ្វ្រេត ខនស្រ្តាក់សិន ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនី ដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព៣៥០មេហ្គាវ៉ាត់ នៅខេត្តពោធិ៍សាត់។

១៦- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ច័ន្ទ និមល ឌីវេឡុបមិន ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនី ដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព១៥០មេហ្គាវ៉ាត់ នៅខេត្តកំពង់ចាម។

១៧- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ម៉ឌើនីធី ហូលឌីង សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនី ដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព១០០មេហ្គាវ៉ាត់ នៅខេត្តកំពង់ឆ្នាំង។

១៨- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន អេច ខេ អូអេស៊ីស ផៅវ៉ែ អេនើជី ឌីវេឡុបមិន ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនី ដើរដោយថាមពលខ្យល់ អានុភាព១៥០មេហ្គាវ៉ាត់ នៅខេត្តមណ្ឌលគិរី។

១៩- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ស្នេថេក ខូ អិលធីឌី សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនី ដើរដោយថាមពលខ្យល់ អានុភាព ១៥០មេហ្គាវ៉ាត់ នៅខេត្តមណ្ឌលគិរី។

២០- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ឥណ្ឌូឆាយណាវីន ផៅវ័រ ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនី ដើរដោយថាមពលខ្យល់ អានុភាព១៥០មេហ្គាវ៉ាត់ នៅខេត្តមណ្ឌលគិរី។

២១- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន លីឌើរ វីន អេនើជី (ខេមបូឌា) ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនី ដើរដោយថាមពលខ្យល់ អានុភាព១៥០មេហ្គាវ៉ាត់ នៅខេត្តមណ្ឌលគិរី។

២២- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន គោព្រៃ វីនហ្វាម ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនី ដើរដោយថាមពលខ្យល់ អានុភាព ១៥០មេហ្គាវ៉ាត់ នៅខេត្តមណ្ឌលគិរី។

២៣- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន បេជីង ហ្វេងហ្គ័ង អ៊ិនហ្វីនីត វីន អេនើជី ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនី ដើរដោយថាមពលខ្យល់ អានុភាព១៥០មេហ្គាវ៉ាត់ នៅខេត្តមណ្ឌលគិរី។

២៤- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន អេសភីអេចភី (ខេមបូឌា) ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនី ដើរដោយថាមពលជីវម៉ាស អានុភាព៥០មេហ្គាវ៉ាត់ និងស្ថានីយផលិតអគ្គិសនី ដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព៤០មេហ្គាវ៉ាត់ ផ្ទួបគ្នា នៅខេត្តកំពង់ស្ពឺ។

២៥- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន បុទុម សាគរ អេនើជី ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនី ដើរដោយឧស្ម័នធម្មជាតិ អានុភាព៩០០មេហ្គាវ៉ាត់ នៅខេត្តកោះកុង។

២៦- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន អេនើស្ទរ ឯ.ក សម្រាប់គម្រោងវិនិយោគវារីអគ្គិសនីព្រែកល្ពាង១ និង២ អានុភាព១១០មេហ្គាវ៉ាត់ នៅខេត្តរតនគិរី។

២៧- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ស្នេថេក ខូ អិលធីឌី សម្រាប់គម្រោងវិនិយោគស្ថានីយប្រព័ន្ធអាគុយស្តុកទុកថាមពល អានុភាព ២០០មេហ្គាវ៉ាត់ នៅខេត្តពោធិ៍សាត់ និងអានុភាព៣០០មេហ្គាវ៉ាត់ នៅខេត្តកំពង់ឆ្នាំង។

២៨- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ស្នេថេក ខូ អិលធីឌី សម្រាប់គម្រោងវិនិយោគស្ថានីយប្រព័ន្ធអាគុយស្តុកទុកថាមពល អានុភាព ៥០០មេហ្គាវ៉ាត់ នៅខេត្តពោធិ៍សាត់។

២៩- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ឆាយណា ណេសិនណល ហៅរី ម៉ាស៊ីនើរី សម្រាប់គម្រោងវិនិយោគវារីអគ្គិសនីបូមទឹកស្តុកទុក អានុភាព១០០០មេហ្គាវ៉ាត់ នៅខេត្តកោះកុង។

៣០- ស្តាប់របាយការណ៍សង្ខេបរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពី សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី២ និងលើកទី៣ ព្រឹទ្ធសភា នីតិកាលទី៥។

៣១- បោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការមហាផ្ទៃ ការពារជាតិ មុខងារសាធារណៈ និងកិច្ចការព្រំដែន និងគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី និង

៣២- ប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី។

- កិច្ចប្រជុំលើកទី១ និងលើកទី២ នៃគណៈកម្មាធិការសមាជរដ្ឋសភា និងព្រឹទ្ធសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានគណៈកម្មាធិការសមាជរដ្ឋសភា និងព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា។
- ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចូលរួមសមាជរដ្ឋសភា និងព្រឹទ្ធសភា លើកទី១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានសមាជរដ្ឋសភា និងព្រឹទ្ធសភា នៅវិមានរដ្ឋសភា។
- **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់បិទសមាជរដ្ឋសភា និងព្រឹទ្ធសភា លើកទី១ នៅវិមានរដ្ឋសភា។
- ប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យឆ្លងសេចក្តីព្រាងសេចក្តីសម្រេចស្តីពី តួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់គណៈកម្មការទាំង១០ ព្រឹទ្ធសភា។
- ប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ ចំនួន២៨ច្បាប់ និង
- ប្រជុំស្តីពី ការធ្វើវិសោធនកម្មច្បាប់បោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

## ២-មុខងារតាមដានការអនុវត្តច្បាប់

- **បានរៀបចំចាត់ចែង និងផ្តល់សេវាជូនគណៈកម្មការនានារបស់ព្រឹទ្ធសភា អញ្ជើញចុះបំពេញបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា៖**
  - ❖ គណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញចុះបំពេញបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់ពីការអនុវត្តច្បាប់ ការដោះស្រាយពាក្យបណ្តឹងរបស់អាជ្ញាធរថ្នាក់ក្រោមជាតិ នៅខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ និងខេត្តសៀមរាប។
  - ❖ គណៈកម្មការទី២ព្រឹទ្ធសភាបាន៖
    - អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់អំពីវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ដោយផ្តោតលើថវិកាថ្នាក់ក្រោមជាតិ បញ្ហាប្រឈម និងសំណូមពរ នៅខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ និង
    - អញ្ជើញជួបពិភាក្សាការងារជាមួយធនាគារជាតិនៃកម្ពុជា ដឹកនាំដោយ **ឯកឧត្តម ស៊ុំ សន្និសិទ្ធ** ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាព និងបញ្ហាប្រឈមក្នុងវិស័យធនាគារ នៅធនាគារជាតិនៃកម្ពុជា។
  - ❖ គណៈកម្មការទី៣ព្រឹទ្ធសភាបាន៖
    - អញ្ជើញពិភាក្សាការងារជាមួយថ្នាក់ដឹកនាំក្រសួង ដឹកនាំដោយ **ឯកឧត្តម ថោ ជេដ្ឋា** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈមឆ្នាំ២០២៤ និងចក្ខុវិស័យរបស់ក្រសួងធនធានទឹក និងឧតុនិយមឆ្នាំ២០២៥ នៅទីស្តីការក្រសួង និង
    - អញ្ជើញជួបពិភាក្សាការងារជាមួយអាជ្ញាធរខេត្តព្រះសីហនុ ដើម្បីសិក្សាឈ្វេងយល់ និងប្រមូលព័ត៌មានពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការទី៣ព្រឹទ្ធសភា នៅខេត្តព្រះសីហនុ។
  - ❖ គណៈកម្មការទី៤ព្រឹទ្ធសភាបាន៖
    - អញ្ជើញចុះជួបពិភាក្សាការងារជាមួយអាជ្ញាធរខេត្តព្រះវិហារ ដើម្បីសិក្សាឈ្វេងយល់អំពីប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធលើកិច្ចប្រតិបត្តិការរបស់ខេត្ត។
    - អញ្ជើញជួបពិភាក្សាការងារជាមួយ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីសិក្សាឈ្វេងយល់អំពីវឌ្ឍនភាពការងារ និងទិសដៅការងារបន្តរបស់ក្រសួងឆ្នាំ២០២៥ នៅទីស្តីការក្រសួងមហាផ្ទៃ។
    - អញ្ជើញចុះជួបពិភាក្សាការងារជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងមន្ត្រីដែលមានសមត្ថកិច្ចពាក់ព័ន្ធ និងដើម្បីសិក្សាឈ្វេងយល់អំពីការចុះបញ្ជីអត្រានុកូលដ្ឋាន និងការអនុវត្តច្បាប់ និងតុលាការ នៅខេត្តស្វាយរៀង និង

- អញ្ជើញជួបពិភាក្សាការងារជាមួយ **ឯកឧត្តមនាយឧត្តមសេនីយ៍ ទៀ សីហា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ និងទិសដៅការងាររបស់ក្រសួងឆ្នាំ២០២៥ នៅទីស្តីការក្រសួងការពារជាតិ។

❖ គណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញចុះជួបពិភាក្សាការងារជាមួយរដ្ឋបាលខេត្តព្រះសីហនុ និងរដ្ឋបាលខេត្តកំពតអំពី៖

- ការអនុវត្តច្បាប់អន្តោប្រវេសន៍ និងការគ្រប់គ្រងជនបរទេស។
- ការអនុវត្តច្បាប់ស្តីពី របបសារព័ត៌មាន និងការគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់ខេត្ត ដូចជា វិទ្យុ ទូរទស្សន៍ និងព័ត៌មានតាមបណ្តាញសង្គម។
- ការផ្តល់ប័ណ្ណការងារ និងការត្រួតពិនិត្យប័ណ្ណការងាររបស់ជនបរទេស ដែលកំពុងធ្វើការនៅតាមរោងចក្រ សហគ្រាស និងក្រុមហ៊ុននានា។
- កិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិជាមួយអាជ្ញាធរប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិនៃប្រទេសជិតខាង។
- ការអភិវឌ្ឍលើវិស័យនានារបស់ខេត្តទាំងពីរ និង
- ការពង្រឹងពង្រីកទំនាក់ទំនងកាន់តែជិតស្និទ្ធរវាងព្រឹទ្ធសភា ជាមួយអាជ្ញាធរខេត្តទាំងពីរគ្រប់លំដាប់ថ្នាក់។

❖ គណៈកម្មការទី៦ព្រឹទ្ធសភាបាន៖

- អញ្ជើញចុះបេសកកម្ម ដើម្បីជួបពិភាក្សាការងារជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀននាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងមន្ត្រីដែលមានសមត្ថកិច្ចពាក់ព័ន្ធនៅតាមមូលដ្ឋាន អំពីការពង្រឹងប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ ការចុះបញ្ជីកំណើត ការចុះបញ្ជីមរណភាព និងការចុះបញ្ជីអាពាហ៍ពិពាហ៍ជូនប្រជាពលរដ្ឋ នៅស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង ដោយមានអ្នកចូលរួម ចំនួន១៥០នាក់ និងបានរៀបចំសម្ភារៈ ឯកសារ ព្រមទាំងបានឧបត្ថម្ភថវិកាក្នុងម្នាក់ៗ ចំនួន៤០,០០០រៀល។
- អញ្ជើញជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំខេត្ត ដោយផ្តោតសំខាន់ទៅលើស្ថានភាពការអភិវឌ្ឍរបស់ខេត្ត និងការអនុវត្តច្បាប់ក្នុងការផ្តល់សេវាសាធារណៈ ជូនប្រជាពលរដ្ឋនៅខេត្តស្វាយរៀង និង
- អញ្ជើញជួបពិភាក្សាការងារជាមួយសាលាដំបូង និងអយ្យការអមសាលាដំបូង ដើម្បីឈ្វេងយល់អំពីការអនុវត្តច្បាប់ក្នុងការផ្តល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋ នៅខេត្តស្វាយរៀង និងរាជធានីភ្នំពេញ។

❖ គណៈកម្មការទី៧ព្រឹទ្ធសភាបាន៖

- អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម វិធានការ និងចក្ខុវិស័យពាក់ព័ន្ធវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តមណ្ឌលគិរី ខេត្តរតនគិរី និងខេត្តស្ទឹងត្រែង និង

- អញ្ជើញជួបពិភាក្សាការងារជាមួយ **ឯកឧត្តម ហួត ហាក់** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ដើម្បីសិក្សាឈ្វេងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម វិធានការ និងចក្ខុវិស័យ របស់ក្រសួង នៅសាលប្រជុំក្រសួងទេសចរណ៍។

❖ គណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចុះបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់ និងប្រមូលព័ត៌មានអំពីការផ្សព្វផ្សាយច្បាប់ និងការអនុវត្តច្បាប់ពាក់ព័ន្ធនឹងវិស័យជំនាញជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តមណ្ឌលគិរី ខេត្តរតនគិរី និងខេត្តស្ទឹងត្រែង។

❖ គណៈកម្មការទី៩ព្រឹទ្ធសភាបាន៖

- អញ្ជើញជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំក្រសួងរ៉ែ និងថាមពល ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងពាណិជ្ជកម្ម ដើម្បីសិក្សាឈ្វេងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម និងផែនការសកម្មភាព នៅទីស្តីការក្រសួង និងទីស្តីការរដ្ឋលេខាធិការដ្ឋាន និង
- អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីឈ្វេងយល់អំពីដំណើរការប្រតិបត្តិនៃទំនប់វារីអគ្គិសនីសេសានក្រោម២ ស្ថានីយផលិតថាមពលអគ្គិសនី ដើរដោយពន្លឺព្រះអាទិត្យ ព្រមទាំងវឌ្ឍនភាពការងារដែលអាជ្ញាធរខេត្តសម្រេចបាន បញ្ហាប្រឈម និងផែនការសកម្មភាពរបស់អាជ្ញាធរខេត្ត និងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព នៅខេត្តស្ទឹងត្រែង និងខេត្តកំពង់ស្ពឺ។

❖ គណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយអង្គភាពប្រឆាំងអំពើពុករលួយ នៅទីស្តីការអង្គភាពប្រឆាំងអំពើពុករលួយ និងបានអញ្ជើញចុះបំពេញបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់អំពីប្រសិទ្ធភាព និងបញ្ហាប្រឈមនៃការអនុវត្តច្បាប់ស្តីពី ការប្រឆាំងអំពើពុករលួយ និងវឌ្ឍនភាព បញ្ហាប្រឈម និងទិសដៅការងារបន្ត របស់រដ្ឋបាលខេត្តតាកែវ និងខេត្តព្រៃវែង។

## ៣-មុខងារតំណាង

- **បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា៖**

**❖ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភាបាន៖**

- **សកម្មភាពចុះមូលដ្ឋាន៖**
  - អញ្ជើញជួបប្រជុំជាមួយមេបញ្ជាការអង្គភាពចំណុះទិសទី២ និងទិសទី៣ នៅទីបញ្ជាការស្រាលទិសទី៣ ក្រុងសំរោង ខេត្តឧត្តរមានជ័យ។
  - អញ្ជើញជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្រុក ក្រុង នៅខេត្តឧត្តរមានជ័យ ចំនួន២៤៨នាក់។
  - អញ្ជើញជួបប្រជុំជាមួយមេបញ្ជាការអង្គភាព និងយោធិនប្រចាំទិសទី១ នៅបញ្ជាការដ្ឋានអង្គរក្សជួរមុខទិសទី១ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។

- អញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខជនភៀសខ្លួន នៅទីទួលសុវត្ថិភាព នៅវត្តពោធិ៍៥០០០ដើម ខេត្តព្រះវិហារ និង
- អញ្ជើញជួបសំណេះសំណាលជាមួយសមាជិក សមាជិកាក្រុមប្រឹក្សា ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ខេត្តព្រះវិហារ ចំនួន៤៦៤នាក់ នៅសាលាខេត្តព្រះវិហារ។

▪ **សកម្មភាពចូលរួមពិធីផ្សេងៗ៖** អញ្ជើញចូលរួមជាអធិបតី និងដង្ហែ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីនានា ចំនួន២០លើក។

❖ **ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី១ព្រឹទ្ធសភាបាន៖**

▪ **សកម្មភាពដឹកនាំ និងចូលរួមកិច្ចប្រជុំ៖**

- អញ្ជើញចូលរួមកិច្ចប្រជុំរួមរវាងតំណាងព្រឹទ្ធសភា ជាមួយក្រុមប្រឹក្សាធម្មនុញ្ញស្តីពីសេចក្តីព្រាងវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៅសាលប្រជុំក្រុមប្រឹក្សាធម្មនុញ្ញ។
- អញ្ជើញដឹកនាំកិច្ចប្រជុំជាមួយ ឯកឧត្តម លោកជំទាវ ជាទីប្រឹក្សារបស់ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា និងកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ និង
- អញ្ជើញដឹកនាំកិច្ចប្រជុំការងាររួមជាមួយទីប្រឹក្សា និងសមាជិកខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។

▪ **សកម្មភាពចុះមូលដ្ឋាន៖**

- អញ្ជើញចុះជួបសំណេះសំណាល សួរសុខទុក្ខ អាជ្ញាធរមូលដ្ឋាន កងកម្លាំងឈរជើងជួរមុខ នៅតាមខ្សែបន្ទាត់ព្រំដែន ពិនិត្យហេដ្ឋារចនាសម្ព័ន្ធ និងជាអធិបតីក្នុងពិធីផ្សេងៗ ចំនួន៦លើក នៅខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តកណ្តាល និងខេត្តព្រះវិហារ និង
- ណែនាំ និងចាត់សមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ទីប្រឹក្សា និងមន្ត្រីខុទ្ទកាល័យ **ឯកឧត្តម** អនុប្រធានទី១ព្រឹទ្ធសភា ចំនួន៧លើក ចុះជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ និងសហការជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តរបស់ក្រុមហ៊ុន Laboratoire Bioderma សាធារណរដ្ឋបារាំង ពិនិត្យព្យាបាលជំងឺ ជូនប្រជាពលរដ្ឋ ដោយឥតគិតថ្លៃ ចំនួន២៦៩នាក់ និងពិនិត្យការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធនានា នៅខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាម។

▪ **សកម្មភាពចូលរួមពិធីផ្សេងៗ៖** អញ្ជើញជាអធិបតី និងចូលរួមជាកិត្តិយសក្នុងពិធីផ្លូវការផ្សេងៗ ចំនួន១៧លើក។

❖ **ឯកឧត្តមបណ្ឌិត ឆន់ ខន្ធសារ អនុប្រធានទី២ព្រឹទ្ធសភាបាន៖**

▪ **សកម្មភាពដឹកនាំកិច្ចប្រជុំ៖** អញ្ជើញជាអធិបតីដឹកនាំកិច្ចប្រជុំការងារសំខាន់ៗរបស់ព្រឹទ្ធសភា ចំនួន១០លើក។

▪ **សកម្មភាពចុះមូលដ្ឋាន៖** អញ្ជើញចុះជួបសំណេះសំណាល សួរសុខទុក្ខ អាជ្ញាធរមូលដ្ឋាន កងកម្លាំងឈរជើងជួរមុខ នៅតាមខ្សែបន្ទាត់ព្រំដែន ពិនិត្យហេដ្ឋារចនាសម្ព័ន្ធ និងជាអធិបតីក្នុងពិធីផ្សេងៗ ចំនួន៧លើក នៅរាជធានីភ្នំពេញ ខេត្តកំពង់ធំ និងខេត្តព្រះវិហារ។

- **សកម្មភាពចូលរួមពិធីផ្សេងៗ៖** អញ្ជើញជាអធិបតី និងចូលរួមជាកិត្តិយសក្នុងពិធីផ្លូវការផ្សេងៗ ចំនួន៣៥លើក។

❖ **សមាជិក សមាជិកាព្រឹទ្ធសភាបាន៖**

- អញ្ជើញជាអធិបតី គណៈអធិបតី និងចូលរួមសិក្ខាសាលា ចំនួន៩លើក ស្ដីពី៖
  ១/ វឌ្ឍនភាពនៃការចុះបញ្ជីដីធ្លី-បរិយាកាសគ្មានវិវាទ។
  ២/ សេចក្ដីប្រកាសនយោបាយក្រោយកិច្ចប្រជុំកម្រិតខ្ពស់របស់អង្គការសហប្រជាជាតិស្ដីពី ជំងឺរបេង (UNHLM-TB) និងរបាយការណ៍ស្ដីពី អភិបាលកិច្ចជំងឺរបេងឆ្នាំ២០២៤។
  ៣/ ប្រាក់រៀល ប្រព័ន្ធបាគង និងខេអេចឃ្យូអរ(KHQR) និងពិធីអបអរសាទរទិវាប្រាក់រៀល ខួបលើកទី៤៥ នៃការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ (២០ មីនា ១៩៨០- ២០ មីនា ២០២៥)។
  ៤/ អំពីសមិទ្ធផលការទូតសភារបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៥ ឆ្នាំ២០២៤។
  ៥/ បម្រែបម្រួលប្រជាសាស្ត្រ និងជំងឺមិនឆ្លង៖ គោលនយោបាយ ឆ្លើយតបបញ្ហាប្រឈម សម្រាប់ប្រជាជនសកម្ម និងយុវជន។
  ៦/ ការពិនិត្យឡើងវិញ និងការវិភាគមុខងារ និងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន។

  ៧/ ការឈ្វេងយល់អំពីក្របខណ្ឌយុទ្ធសាស្ត្រក្នុងការអនុវត្តកម្មវិធីសកម្មភាពនៃសន្និសីទអន្តរជាតិស្ដីពី ប្រជាជន និងការអភិវឌ្ឍ-ICPD PoA។
  ៨/ លទ្ធផលនៃកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់កម្ពុជា និងសភាពការណ៍អន្តរជាតិ និង
  ៩/ ការកំណត់លក្ខខណ្ឌនៃការប្រើប្រាស់ដី និងការគ្រប់គ្រងនគរូបនីយកម្ម និងសំណង់ក្នុងតំបន់រមណីយដ្ឋានបេតិកភណ្ឌពិភពលោក។
- អញ្ជើញចូលរួមវេទិកា ចំនួន៤លើក ស្ដីពី៖
  ១/ ការពង្រឹងសមត្ថភាពដឹកនាំក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី និងសហគ្រិនជាស្ត្រី រួមទាំងវិស័យឌីជីថល។
  ២/ វឌ្ឍនភាព វិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ តាមរយៈការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល។
  ៣/ វេទិកាសាធារណៈ ដើម្បីស្ដាប់សំណូមពរ និងកង្វល់នានារបស់ប្រជាពលរដ្ឋ ពាក់ព័ន្ធការអនុវត្តគោលនយោបាយភូមិ សង្កាត់ មានសុវត្ថិភាព និង
  ៤/ ប្រព័ន្ធគាំពារសង្គមនៅកម្ពុជា។
- អញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធី ចំនួន៣លើក រួមមាន៖
  ១/ សម្ពោធមហាកុដិ **សម្ដេចព្រះសង្ឃរាជ ជួន ណាត** និងអភិវក្យសាស្ត្រាស្លឹករឹតខ្មែរ ព្រមទាំងសមិទ្ធផលនានា។
  ២/ ច្រត់ព្រះនង្គ័ល និង

៣/ ទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត របស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅរាជធានីភ្នំពេញ និងខេត្តកំពង់ឆ្នាំង។

- អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗ ចំនួន១៣លើក រួមមានៈ

១/ ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារសិក្សា ចំនួន១ខ្នង នៃវិទ្យាល័យ ហេង សំរិន។

២/ ពិធីសម្ពោធអគារសិក្សា ចំនួន១ខ្នង ជាអំណោយអង្គការសប្បុរសជនជាតិជប៉ុន។

៣/ ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៤ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

៤/ ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពី ប្រតិបត្តិការរវាងគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេតនៃព្រឹទ្ធសភា ជាមួយក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែន។

៥/ ពិធីប្រគល់-ទទួលសម្ភារៈវេជ្ជសាស្ត្រ ឱសថ និងសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ ដែលជាជំនួយមនុស្សធម៌របស់មូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ ( Global Life Sharing ) ជូនរដ្ឋបាលខេត្តកណ្តាល។

៦/ ពិធីប្រគល់-ទទួលម៉ាស៊ីនលាងឈាម និងបរិក្ខារពេទ្យ ជូនដល់ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

៧/ ពិធីក្រុងពាលី និងចុះអនុស្សរណៈសាងសង់អគារសិក្សា១ខ្នង មានចំនួន៥បន្ទប់ ដែលជាអំណោយរបស់សមាគមមូលនិធិទូទៅ ដើម្បីសុខុមាលភាពជាតិ និងជួយគ្នាទៅវិញទៅមក។

៨/ ពិធីបុណ្យវិសាខបូជា។

៩/ ពិធីជួបសវនាការរវាង **លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** អនុប្រធានអចិន្ត្រៃយ៍កាកបាទក្រហមកម្ពុជា ជាមួយគណៈប្រតិភូក្រសួង និងគណៈប្រតិភូក្រុមហ៊ុនចំនួន៦ ក្នុងឱកាសខួបទី១៦២ ទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ៨ ឧសភា ឆ្នាំ២០២៥ និងខួបលើកទី៧០ឆ្នាំនៃកាកបាទក្រហមកម្ពុជា ក្រោមមូលបទរួមគ្នាស្ម័គ្រចិត្ត ដើម្បីសហគមន៍មានសុខភាពល្អ និងមានភាពធន់នឹងអាកាសធាតុ។

១០/ ខួបលើកទី១១៤ ទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០២៥ ក្រោមប្រធានបទ "សិទ្ធិ សមភាព និងភាពអង់អាច ចំពោះស្ត្រី និងក្មេងស្រីគ្រប់រូប"។

១១/ ទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

១២/ ពិធីមីទ្ទិញអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៦ នៃទិវាជ័យជម្នះ ៧ មករា ១៩៧៩-៧ មករា ២០២៥ និង

១៣/ ពិធីសម្ពោធឆ្លងអគារសិក្សា និងសមិទ្ធផលនានា ក្នុងវត្តព្រះឥន្ទសាមគ្គីធម៌។

- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ និងក្រុមសមាជិកាព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាល ចំនួន៦១លើក ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម សំណូមពរ ការអនុវត្តគោលនយោបាយនានា នាំយកអំណោយ និងចូលរួមដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ នៅតាមបណ្តាភូមិភាគទាំង៨។
- អញ្ជើញចុះជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកនូវជំនួយឧបត្ថម្ភ ជូនបងប្អូនវីរយុទ្ធជនជួរមុខការពារព្រំដែន នៅខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ។
- អញ្ជើញចូលរួមកិច្ចប្រជុំ ចំនួន៨លើក ស្តីពីៈ
  ១/ ការគ្រប់គ្រង និងការអភិរក្សដីសមូហភាពរបស់ជនជាតិដើមភាគតិច និងបញ្ហាផ្សេងៗ។
  ២/ បូកសរុបលទ្ធផលការងារចន្លោះសម័យប្រជុំ និងការពង្រឹងគណនេយ្យភាពសមាជិកព្រឹទ្ធសភា ជាមួយអង្គបោះឆ្នោត ចំនួន២លើក។
  ៣/ ការកៀរគរឆន្ទៈនយោបាយក្នុងការអនុវត្តរបៀបវារៈស្តីពី ស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា។
  ៤/ រៀបចំទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ៨ ឧសភា ឆ្នាំ២០២៥ និងខួបលើកទី៧០ នៃកាកបាទក្រហមកម្ពុជា។
  ៥/ ប្រកាសសមាសភាពគណៈកម្មការរៀបចំគណៈប្រតិភូសភាកម្ពុជា ចូលរួម AIPA Causcus លើកទី១៦ និងសមាសភាពសមាជិកសភាយែក្មេងអាយប៉ា (AIPA) ដែលត្រូវចូលរួមកម្មវិធី AIPA Roadshow។
  ៦/ ការត្រៀមរៀបចំកម្មវិធីលើកកម្ពស់ការយល់ដឹងអំពីបញ្ញាសិប្បនិម្មិត (AI) និងអភិបាលកិច្ចឌីជីថល (Digital Governance) សម្រាប់ស្ថាប័នព្រឹទ្ធសភា។
  ៧/ ត្រៀមរៀបចំសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលស្តីពី ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល ដោយផ្តោតលើការអនុវត្តគោលនយោបាយវិស័យអប់រំ យុវជន និងកីឡា និង
  ៨/ ត្រៀមរៀបចំសន្និបាតរបស់សមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍។
- អញ្ជើញទទួលជួបប្រជាពលរដ្ឋ មកពីខេត្តពោធិ៍សាត់ ខេត្តសៀមរាប និងលោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស មកពីសាលា Milky Way ចំនួន៣០២នាក់ អញ្ជើញមកសិក្សាឈ្វេងយល់អំពីវិស័យកសិកម្ម និងកសិ-ទេសចរណ៍ ហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ ស្ពាន ទំនប់ទឹក និងចំការដំណាំហូបផ្លែច្រើនប្រភេទ នៅខេត្តកំពង់ស្ពឺ។
- អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ចុះពិនិត្យ និងព្យាបាលជំងឺទូទៅជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅរាជធានីភ្នំពេញ ខេត្តព្រៃវែង ខេត្តបាត់ដំបង ខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាម។

- អញ្ជើញធ្វើបទបង្ហាញជូនលោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ចំនួន៥១នាក់ នៃសាលាបញ្ញាសាស្ត្រអន្តរជាតិ មកទស្សនកិច្ចសិក្សាឈ្វេងយល់អំពីរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។
- អញ្ជើញជាវាគ្មិនក្នុងកម្មវិធីធ្វើបទបង្ហាញ ចំនួន២លើក ស្តីពី "រចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា" ជូននិស្សិតនៃសាកលវិទ្យាល័យអាស៊ី-អឺរ៉ុប និងសាកលវិទ្យាល័យវ៉ាន់ដា សរុបចំនួន១១៤នាក់ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។
- អញ្ជើញចូលរួមស្តាប់បទបង្ហាញស្តីពី ការស្រាវជ្រាវ អង្កេត និងវិភាគរបស់សមាគមសហគ្រិនស្ត្រីកម្ពុជាពាក់ព័ន្ធនឹងស្ត្រី ក្រោមអធិបតីភាពរបស់ **លោកជំទាវ មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។
- អញ្ជើញផ្តល់បាឋកថាស្តីពី គោលនយោបាយការបរទេស និងវិស័យការទូតសភា នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង និង
- អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗ ចំនួន៣៥លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជា។
- ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ នៅមូលដ្ឋាន ឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខ សណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអនុវត្តគោលនយោបាយនានា ពិនិត្យហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា **ចំនួន៥៨៩លើក** ព្រមទាំងបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធសមិទ្ធផលនានា និងពិធីផ្លូវការផ្សេងៗ **ចំនួន៨៤៤លើក**។

- **សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖**

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភាបាន៖

- អញ្ជើញចូលរួមអមដំណើរថ្នាក់ដឹកនាំព្រឹទ្ធសភា និងអញ្ជើញចុះបំពេញការងារនៅមូលដ្ឋាន និងចូលរួមពិធីផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ចំនួន១១លើក។
- អញ្ជើញចូលរួមរៀបចំ និងធ្វើសន្និសីទសារព័ត៌មានរួម អំពីលទ្ធផលសមាជរដ្ឋសភា និងព្រឹទ្ធសភា លើកទី១ នៅវិមានរដ្ឋសភា។
- អញ្ជើញប្រគល់អំណោយជូន **លោក ស៊ូ សាវ៉ាង** នាយកប្រតិបត្តិនៃសមាគមចលនាវប្បធម៌ជាតិ ដើម្បីកុមារកំព្រា កុមារក្រីក្រ ក្នុងឱកាសអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ២៥៦៩ នៅវិមានព្រឹទ្ធសភា និង
- អញ្ជើញជាអធិបតី និងចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ចំនួន៤១លើក។

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា **ឯកឧត្តម ខេង សិទ្ធិគុណ** និង**ឯកឧត្តម អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានដឹកនាំគណៈប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញចុះសួរសុខទុក្ខ និងប្រគល់អំណោយឧបត្ថម្ភរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយឧត្តមសេនីយ៍ផុតលេខផ្កាយមាស៥ និងជាប្រធានព្រឹទ្ធសភា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ជូនដល់កងទ័ពជួរមុខ នៅកងពលធំអន្តរាគមន៍លេខ២ និងបានជួបសម្តែងការគួរសមជាមួយ **ឯកឧត្តមនាយឧត្តមសេនីយ៍ កិត្តិសង្គហបណ្ឌិត ហ៊ីង ប៊ុនហៀង** អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងអង្គរក្ស ព្រមទាំងបានជួបសំណេះសំណាលជាមួយកងកម្លាំងឈរជើង នៅប្រាសាទតាមាន់ ខេត្តឧត្តរមានជ័យ។
- **ឯកឧត្តម ខេង សិទ្ធិគុណ** និង**ឯកឧត្តម អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញនាំយកថវិការបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ជូនក្រុមគ្រួសារសព **ឯកឧត្តម មួង ប៉យ** សមាជិកក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ និងជាសមាជិកគណៈកម្មការទី៤ព្រឹទ្ធសភា ព្រមទាំងបានចូលរួមរៀបចំចាត់ចែងពិធីបុណ្យសពតាមប្រពៃណីជាតិ នៅគេហដ្ឋាននៃសព ស្ថិតនៅក្រុងបានលុង ខេត្តរតនគិរី។
- **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភាបាន៖
  - អញ្ជើញចូលរួមអមដំណើរថ្នាក់ដឹកនាំព្រឹទ្ធសភា អញ្ជើញចុះបំពេញការងារនៅមូលដ្ឋាន និងចូលរួមពិធីផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ចំនួន៨លើក និង
  - អញ្ជើញចូលរួមកិច្ចប្រជុំ សន្និសីទ សិក្ខាសាលា និងពិធីផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ចំនួន៦៧លើក។
- **ឯកឧត្តម អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភាបាន៖
  - អញ្ជើញចូលរួមអមដំណើរថ្នាក់ដឹកនាំព្រឹទ្ធសភា អញ្ជើញចុះបំពេញការងារនៅមូលដ្ឋាន និងចូលរួមពិធីផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ចំនួន៣លើក និង
  - អញ្ជើញចូលរួមកិច្ចប្រជុំ សន្និសីទ សិក្ខាសាលា និងពិធីផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ចំនួន៤៥លើក។
- **ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភាបាន៖
  - អញ្ជើញចូលរួមអមដំណើរថ្នាក់ដឹកនាំព្រឹទ្ធសភា អញ្ជើញចុះបំពេញការងារនៅមូលដ្ឋាន និងចូលរួមពិធីផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ចំនួន២លើក។
  - អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសមាគមបេសកកម្មមនុស្សធម៌កម្ពុជា( AMH ) របស់សាធារណរដ្ឋបារាំង ចុះពិនិត្យ និងព្យាបាលជំងឺទូទៅជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ចំនួន២លើក និង

▪ អញ្ជើញជាអធិបតី និងចូលរួមកិច្ចប្រជុំ សន្និសីទ សិក្ខាសាលា និងពិធីផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ចំនួន៤៤លើក។

❖ សមាជិក សមាជិកាសហភាពសហព័ន្ធយុវជនកម្ពុជានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ៣០រូប បានអញ្ជើញចូលរួមបរិច្ចាគឈាម ក្រោមប្រធានបទ "យើងរួមគ្នាបរិច្ចាគឈាម ១,០០០សាក់ ដើម្បីសង្គ្រោះជីវិត" នៅមជ្ឈមណ្ឌលកីឡាកងយោធពលខេមរភូមិន្ទ។

- បានរៀបចំចាត់ចែងបញ្ជូនសារលិខិតថ្វាយព្រះពរ និងលិខិតជូនពរ លិខិតអបអរសាទរ លិខិតថ្លែងអំណរគុណ លិខិតរំលែកទុក្ខ និងកន្រ្តកផ្ការបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ និងគោរពជូន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជា និងឥស្សរជនជាន់ខ្ពស់ជាតិ-អន្តរជាតិ ព្រមទាំងថ្នាក់ដឹកនាំតាមក្រសួង-ស្ថាប័ននានា ក្នុងឱកាសនៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មវស្សា ចម្រើនជន្មាយុ ពិធីទទួលគោរមងារ ពិធីដំឡើងឋានន្តរសក្តិ ថ្នាក់ ពិធីទទួលគ្រឿងឥស្សរិយយស និងពិធីបុណ្យជាតិ-អន្តរជាតិផ្សេងៗ ចំនួន២១៥លិខិត និងចំនួន៤៨កន្រ្តក។
- បានរៀបចំជូនគណៈប្រតិភូព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញចូលរួមក្នុងពិធីគោរពវិញ្ញាណក្ខន្ធ ពិធីបញ្ចុះសព និងពិធីបូជាសព ចំនួន២១លើក។
- បានរៀបចំទទួលដំណើរទស្សនកិច្ច និងធ្វើបទបង្ហាញស្តីពី "រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងសាវតារបស់ព្រឹទ្ធសភា" ប្រគេនព្រះសង្ឃ និងជូនសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត និងសិស្សានុសិស្សមកពីសាលា សមាគម វិទ្យាស្ថាន និងសាកលវិទ្យាល័យនានា ចំនួន៦លើក មានសិក្ខាកាមចំនួន ៤៥៤អង្គ/នាក់។
- បានប្រគល់ថវិកាឧបត្ថម្ភរបស់ព្រឹទ្ធសភា និងឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា ជូនកាកបាទក្រហមកម្ពុជា ក្នុងឱកាសខួបលើកទី១៦២ ទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ៨ ឧសភា ២០២៥ និងខួបលើកទី៧០ឆ្នាំនៃកាកបាទក្រហមកម្ពុជា។
- បានរៀបចំគ្រឿងសក្ការបូជាសម្រាប់រាប់បាត្រប្រគេនព្រះសង្ឃ ចំនួន១៦០កញ្ចប់ ក្នុងពិធីបុណ្យវិសាខបូជា និងអំណោយ ចំនួន៣០កញ្ចប់ ជូនគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ និងអន្តរជាតិ។
- បានសហការរៀបចំកម្មវិធីការដាក់ឱ្យប្រើប្រាស់បណ្ណាល័យមេគង្គ-ឡានឆាង នៅសាលាបឋមសិក្សាព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។
- បានរៀបចំតុបតែងលម្អសង្ក្រាន្ត ការសម្តែងរបាំត្រុដិ ព្រមទាំងបានរៀបចំពិធីសូត្រមន្តចម្រើនព្រះបរិត្ត និងវណ្តាប់ទទួលទេវតាឆ្នាំថ្មី នៅវិមានព្រឹទ្ធសភា ក៏ដូចជាអាហារសាមគ្គី ក្នុងឱកាសអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ២៥៦៩ និង
- បានទទួលពាក្យបណ្តឹង ចំនួន៥៣បណ្តឹង ធ្វើកំណត់បង្ហាញពាក្យបណ្តឹង ចំនួន៣៨បណ្តឹង បញ្ជូនពាក្យបណ្តឹងទៅក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែន ចំនួន២បណ្តឹង ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីក្រសួង ស្ថាប័នពាក់ព័ន្ធ ចំនួន១៣បណ្តឹង កំពុងពិនិត្យសិក្សា ចំនួន២បណ្តឹង

បញ្ជូនពាក្យបណ្តឹងទៅក្រសួង ស្ថាប័ន និងខេត្តពាក់ព័ន្ធ ចំនួន៤២បណ្តឹង ផ្តល់ព័ត៌មានទៅម្ចាស់បណ្តឹង ចំនួន៥៨បណ្តឹង ទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ចំនួន១៦បណ្តឹង និងតម្កល់ទុកមិនចាត់ការ ចំនួន១៤បណ្តឹង។

## ៤-មុខងារសហប្រតិបត្តិការអន្តរជាតិ

- **បានរៀបចំចាត់ចែង និងផ្តល់សេវាជូនប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា៖**

❖ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា៖**

- **ការទទួលសារតាំង៖ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងនាមជាប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា បានទទួលសារតាំងពី **ឯកឧត្តម ធុល ត្រៃសូរ៉ាត់** ឯកអគ្គរាជទូតនៃព្រះរាជាណាចក្រថៃ ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅវិមានព្រឹទ្ធសភា។
- **បដិសណ្ឋារកិច្ចភ្ញៀវជាតិ-អន្តរជាតិ៖** បានអនុញ្ញាតឱ្យភ្ញៀវជាតិ-អន្តរជាតិ និងអង្គទូតនានា ចូលជួបសម្តែងការគួរសម សំណេះសំណាល និងពិភាក្សាការងារ **ចំនួន២៨លើក** រួមមាន៖

  + **បដិសណ្ឋារកិច្ចភ្ញៀវជាតិ៖** បានអនុញ្ញាតឱ្យភ្ញៀវជាតិ ចូលជួបសម្តែងការគួរសម សំណេះសំណាល និងពិភាក្សាការងារ ចំនួន៣លើក៖

    ១/ សមាជិកព្រឹទ្ធសភាមកពីគណបក្សឆន្ទៈខ្មែរ ចំនួន៣រូប។

    ២/ ប្រធានក្រុមប្រឹក្សាភិបាលសម្ព័ន្ធសមាគមមូលនិធិសម្តេចតេជោ និង

    ៣/ ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី។

  + **បដិសណ្ឋារកិច្ចភ្ញៀវអន្តរជាតិ៖** បានអនុញ្ញាតឱ្យភ្ញៀវអន្តរជាតិ និងអង្គទូត ចូលជួបសម្តែងការគួរសម សំណេះសំណាល និងពិភាក្សាការងារ ចំនួន២៥លើក រួមមាន៖

    - ជំនួបជាមួយភ្ញៀវអន្តរជាតិ ចូលជួបសម្តែងការគួរសម ចំនួន១១លើក៖

      ១/ រដ្ឋទាយាទនៃបូរីក្សត្រលុចសំបួ។

      ២/ ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន។

      ៣/ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ។

      ៤/ សមាជិកសភាជប៉ុន និងជាអតីតរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្មជប៉ុន។

      ៥/ ស្ថាបនិកអង្គការសម្ព័ន្ធយុវជនអន្តរជាតិ International Youth Fellowship (IYF)។

      ៦/ អគ្គលេខាធិការនៃសន្និសីទប្រធានសភានៃអន្តរសភា(ISC)។

      ៧/ អគ្គរដ្ឋអាជ្ញានៃសហព័ន្ធរុស្ស៊ី។

      ៨/ នាយកប្រតិបត្តិសាជីវកម្មទេសចរជប៉ុន។

      ៩/ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ សិល្បៈ និងវប្បធម៌នៃប្រទេសម៉ាឡេស៊ី។

      ១០/ អនុរដ្ឋមន្ត្រីក្រសួងការពារប្រទេសវៀតណាម និងជាអគ្គសេនាធិការនៃកងទ័ពប្រជាជនវៀតណាម និង

១១/ មេបញ្ជាការកងស្វ័យការពារជើងគោកជប៉ុន។

- ជំនួបឯកអគ្គរដ្ឋ/រាជទូតវិសាមញ្ញ និងពេញសមត្ថភាព ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមាននិវេសនដ្ឋាន នៅរាជធានីភ្នំពេញ ចំនួន៥លើក៖

  ១/ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋសិង្ហបុរី។

  ២/ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឥណ្ឌា។

  ៣/ ឯកអគ្គរដ្ឋទូតនៃសហព័ន្ធរុស្ស៊ី។

  ៤/ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និង

  ៥/ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដេស។

- ជំនួបឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមាននិវេសនដ្ឋាន នៅក្រៅប្រទេស ចំនួន១លើក គឺ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឥស្លាមអ៊ីរ៉ង់។

- ជំនួបជាមួយភ្ញៀវអន្តរជាតិក្នុងវិស័យសាធារណៈ ចំនួន៦លើក៖

  ១/ **ឯកឧត្តមបណ្ឌិត តាន់ស្រ៊ី ដាតូ ចូហារិ ប៊ិន អាប់ឌុល** ប្រធានរដ្ឋសភានៃប្រទេសម៉ាឡេស៊ី នៅវិមានព្រឹទ្ធសភា។

  ២/ **លោកជំទាវ ម៉ាតា ម៉ាត្រៃ** អនុប្រធានទី១នៃសភាជាតិហុងគ្រី នៅវិមានព្រឹទ្ធសភា។

  ៣/ គណៈប្រតិភូកុងស៊ុលកិត្តិយសអឺរ៉ុប ដឹកនាំដោយ **លោកបណ្ឌិត សាឡូ អ៊ីសា** កុងស៊ុលកិត្តិយសនៃសាធារណរដ្ឋស៊ីប (Cyprus) ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅវិមានព្រឹទ្ធសភា។

  ៤/ **ឯកឧត្តម ជែម កាម៉ាល់ខាន់** រដ្ឋមន្ត្រីពាណិជ្ជកម្មនៃសាធារណរដ្ឋឥស្លាមប៉ាគីស្ថាន នៅវិមានព្រឹទ្ធសភា។

  ៥/ **ឯកឧត្តម គីម ជីនព្យូ** អតីតប្រធានរដ្ឋសភានៃសាធារណរដ្ឋកូរ៉េ និងជាប្រធានក្រុមប្រឹក្សាអង្គការដើម្បីពិភពលោកទាំងអស់គ្នា (Global Together) នៅវិមាន៧មករា និង

  ៦/ **ឯកឧត្តម យីន លី** សមាជិកការិយាល័យនយោបាយ និងជាលេខាធិការនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិន ប្រចាំនៅរដ្ឋធានីប៉េកាំង នៅវិមាន៧មករា។

- ជំនួបជាមួយភ្ញៀវអន្តរជាតិក្នុងវិស័យឯកជន ចំនួន២លើក៖

  ១/ **លោក អេឌី ពីរ៉ាជ** អគ្គនាយក និងជានាយកប្រតិបត្តិ (CEO) ក្រុមហ៊ុន Japan Tobacco International (JTI) សកលលោក នៅវិមានព្រឹទ្ធសភា និង

  ២/ **លោកសាស្ត្រាចារ្យ តេតស៊ុយ៉ា វ៉ាតាណាបេ** និងគណៈប្រតិភូវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់កិច្ចការអាស៊ាន និងអាស៊ីបូព៌ា (ERIA) នៅវិមាន៧មករា។

- **សកម្មភាពការងារនៅក្រៅប្រទេស៖**
  - បានអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការនៅក្រៅប្រទេស **ចំនួន៤លើក** រួមមាន៖

១/ អញ្ជើញដឹកនាំគណៈប្រតិភូកម្ពុជា បំពេញទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។ ក្នុងឱកាសនោះ **សម្ដេចតេជោ** បាន៖

+ ជួបពិភាក្សាការងារជាមួយ៖
  - **ឯកឧត្តមបណ្ឌិត សៃស៊ុមផន ភុមវិហាន** ប្រធានរដ្ឋសភានៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។
  - **ឯកឧត្តម សនសៃ ស៊ីផាន់ដន** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និង
  - **ឯកឧត្តម ថងលុន ស៊ីសុលីត** អគ្គលេខាធិការបក្សប្រជាជនបដិវត្តន៍ឡាវ ក្នុងកិច្ចប្រជុំកំពូលលើកទី១៥ រវាងគណបក្សប្រជាជនបដិវត្តន៍ឡាវ និងគណបក្សប្រជាជនកម្ពុជា នៅសាលសន្និបាតជាតិ រដ្ឋធានីវៀងចន្ទន៍។
+ អញ្ជើញចូលរួមពិធីដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធ នៅស្តូបអនុស្សាវរីយ៍វីរជនពលី។
+ អញ្ជើញទស្សនាអគារវិមានរដ្ឋសភាជាតិឡាវ និងបានអញ្ជើញដាំដើមឈើជាអនុស្សាវរីយ៍ និង
+ អញ្ជើញចូលរួមពិធីលៀងសាយភោជន៍ផ្លូវការ ដែលរៀបចំដោយ **ឯកឧត្តមបណ្ឌិត សៃស៊ុមផន ភុមវិហាន** ប្រធានរដ្ឋសភានៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

២/ អញ្ជើញដឹកនាំគណៈប្រតិភូកម្ពុជា ចូលរួមកិច្ចប្រជុំកំពូលបក្សទ្វេភាគី កម្ពុជា-វៀតណាម និងត្រីភាគី កម្ពុជា-ឡាវ-វៀតណាម នៅទីក្រុងហូជីមិញ សាធារណរដ្ឋសង្គមនិយមវៀតណាម។ ក្នុងឱកាសនោះ **សម្ដេចតេជោ** បានអញ្ជើញជួបពិភាក្សាការងារជាមួយ៖

  - **ឯកឧត្តម តូ ឡឹម** អគ្គលេខាធិការមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម នៅទីក្រុងហូជីមិញ និង
  - **ឯកឧត្តម ថងលុន ស៊ីសូលីត** អគ្គលេខាធិការបក្សប្រជាជនបដិវត្តន៍ឡាវ នៅទីក្រុងហូជីមិញ។

៣/ អញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជា ចូលរួមខួបអនុស្សាវរីយ៍លើកទី៥០ នៃទិវារំដោះភាគខាងត្បូង និងបង្រួបបង្រួមជាតិវៀតណាម នៅទីក្រុងហូជីមិញ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។ ក្នុងឱកាសនោះ **សម្ដេចតេជោ** បានជួបពិភាក្សាការងារទ្វេភាគីជាមួយ៖

  - **ឯកឧត្តម តូ ឡឹម** អគ្គលេខាធិការមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម។

- **ឯកឧត្តម ផាម មិញជិញ** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និង
- **ឯកឧត្តម ជិន ថាញ់មិន** ប្រធានរដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

៤/ អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាកម្ពុជា បំពេញទស្សនកិច្ចការងារ នៅសាធារណរដ្ឋឥណ្ឌូណេស៊ី និងទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេះ

៤.១- ក្នុងឱកាសបំពេញទស្សនកិច្ចការងារ នៅសាធារណរដ្ឋឥណ្ឌូណេស៊ី **សម្តេចតេជោ** បានៈ

+ ជួបពិភាក្សាការងារជាមួយៈ
  - **ឯកឧត្តម ប្រាបូវ៉ូ ស៊ូប៊ីយ៉ាន់តូ** ប្រធានាធិបតីនៃសាធារណរដ្ឋឥណ្ឌូណេស៊ី។
  - **ឯកឧត្តម កៅ គឹមហួន** អគ្គលេខាធិការអាស៊ាន តំណាងអចិន្ត្រៃយ៍ប្រទេសសមាជិកអាស៊ានទាំងអស់ និងលោកជំទាវឯកអគ្គរដ្ឋទូតទីម័រឡេស្តេប្រចាំអាស៊ាន នៅលេខាធិការដ្ឋានអាស៊ាននៃរដ្ឋធានីហ្សាការតា។
  - **ឯកឧត្តមបណ្ឌិត មហាមេដ យូសុសកាឡា** អតីតអនុប្រធានាធិបតីឥណ្ឌូណេស៊ី និងជាប្រធានប្រតិបត្តិអង្គការអ្នកប្រជាធិបតេយ្យនិយមកណ្តាលអាស៊ី-ប៉ាស៊ីហ្វិក។
  - **លោកសាស្ត្រាចារ្យបណ្ឌិត ដាតុ ស្រ៊ី ថាហ៊ា** សមាជិកក្រុមប្រឹក្សាពិគ្រោះយោបល់របស់ប្រធានាធិបតីឥណ្ឌូណេស៊ី និងស្ថាបនិកក្រុមហ៊ុន Mayapada Group។
  - **លោកជំទាវ ពាន់ ម៉ាហារ៉ានី** ប្រធានរដ្ឋសភានៃសាធារណរដ្ឋឥណ្ឌូណេស៊ី នៅវិមានរដ្ឋសភានៃរដ្ឋធានីហ្សាការតា និង
  - **ឯកឧត្តម ស៊ុលតាន់ បាកទីយ៉ា ណាជាមូឌីន** ប្រធានព្រឹទ្ធសភានៃសាធារណរដ្ឋឥណ្ឌូណេស៊ី នៅវិមានព្រឹទ្ធសភានៃរដ្ឋធានីហ្សាការតា។
+ អញ្ជើញចូលរួមខួបលើកទី២៦ នៃព្រះរាជាណាចក្រកម្ពុជា ចូលជាសមាជិកអាស៊ាន និងបានធ្វើបាឋកថា ក្រោមប្រធានបទៈ "កម្ពុជា និងអាស៊ាន, អាស៊ាន និងពិភពលោក" នៅរដ្ឋធានីហ្សាការតា។
+ អញ្ជើញផ្តល់បាឋកថា ក្រោមប្រធានបទៈ "ទស្សនៈ និងបទពិសោធនៃកិច្ចខិតខំកសាងសន្តិភាពនៅកម្ពុជា" នៅវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ច (ERIA) និងអាស៊ីបូព៌ា រដ្ឋធានីហ្សាការតា និង
+ អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាកម្ពុជា ទស្សនាវិមានរដ្ឋសភាឥណ្ឌូណេស៊ី នៅរដ្ឋធានីហ្សាការតា។

៤.២- ក្នុងឱកាសបំពេញទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋប្រជាធិបតេយ្យ ទីម័រឡេស្តេ **សម្តេចតេជោ** បាន៖

+ ជួបពិភាក្សាការងារជាមួយ៖
  - **លោកជំទាវ ម៉ារៀ ហ្វីណាន់ដាឡៃ** ប្រធានរដ្ឋសភានៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ នៅវិមានរដ្ឋសភា ទីក្រុងឌីលី។
  - **ឯកឧត្តម ចូហ្សេ រ៉ាមូស អរតា** ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ នៅវិមានប្រធានាធិបតីនៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ និង
  - **ឯកឧត្តម កៃ រ៉ាឡា សាណាណា ហ្គូសម៉ៅ** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ នៅវិមានរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ។
+ អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាកម្ពុជា ទស្សនាកំពង់ផែ Tibar នៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ។
+ អញ្ជើញធ្វើបាឋកថា ក្រោមប្រធានបទ មេរៀនរបស់ ហ៊ុន សែន៖ "ពីរបបប្រល័យពូជសាសន៍ និងភាពក្រីក្រ ឆ្ពោះទៅកាន់សេរីភាព និងវិបុលភាព" ជូនថ្នាក់ដឹកនាំ និងមន្ត្រីជាន់ខ្ពស់ទីម័រឡេស្តេ នៅវិមានប្រធានាធិបតីទីម័រឡេស្តេ និង
+ អញ្ជើញទទួលគ្រឿងឥស្សរិយយស Grand Collar of the Order of Timor-Leste ដែលជាឥស្សរិយយសកម្រិតខ្ពស់បំផុតរបស់រដ្ឋាភិបាលទីម័រឡេស្តេ។

❖ **ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី១ព្រឹទ្ធសភា៖**

- **សកម្មភាពដឹកនាំកិច្ចប្រជុំ៖**
  - បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈប្រតិភូសភាកម្ពុជា ដើម្បីត្រៀមចូលរួមមហាសន្និបាតសហភាពអន្តរសភា (IPU) លើកទី១៥០ និងកិច្ចប្រជុំពាក់ព័ន្ធ នៅទីក្រុងតាស្កិននៃសាធារណរដ្ឋអ៊ូសបេគីស្ថាន នៅសាលប្រជុំពិសេសទី៣ វិមានព្រឹទ្ធសភា និង
  - បានអញ្ជើញដឹកនាំកិច្ចប្រជុំត្រៀមចូលរួមសម័យប្រជុំប្រចាំឆ្នាំលើកទី៥០ នៃសភាប្រើភាសាបារាំង (APF) នៅទីក្រុងប៉ារីសនៃសាធារណរដ្ឋបារាំង។
- **បដិសណ្ឋារកិច្ចភ្ញៀវជាតិ-អន្តរជាតិ៖** បានអនុញ្ញាតឱ្យភ្ញៀវជាតិ-អន្តរជាតិ និងឯកអគ្គរដ្ឋទូតនៃបណ្តាប្រទេសនានា ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ **ចំនួន៨លើក** រួមមាន៖
  + **បដិសណ្ឋារកិច្ចភ្ញៀវជាតិ៖** បានអនុញ្ញាតឱ្យភ្ញៀវជាតិ ចូលជួបសម្តែងការគួរសមចំនួន៣លើក៖

    ១/ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី។

    ២/ ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ និង

៣/ ឯកឧត្តម លោកជំទាវ ជាសមាជិក សមាជិកាព្រឹទ្ធសភា។

+ **បដិសណ្ឋារកិច្ចភ្ញៀវអន្តរជាតិ៖** បានអនុញ្ញាតឱ្យភ្ញៀវអន្តរជាតិ និងឯកអគ្គរដ្ឋទូតនៃបណ្តាប្រទេសនានា ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ចំនួន៥លើក៖

១/ ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ី។

២/ គណៈប្រតិភូគណៈកម្មាធិការសម្រាប់ភាពជាអ្នកជិតខាងល្អ មិត្តភាព និងកិច្ចសហប្រតិបត្តិការនៃអង្គការសហប្រតិបត្តិការសៀងហៃ(GNFCC)។

៣/ ប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ។

៤/ នាយកប្រតិបត្តិសមាគមចិន និងគណៈកម្មការសេដ្ឋកិច្ចពាណិជ្ជកម្មអាស៊ី-បាស៊ីហ្វិក និង

៥/ សមាគមនិស្សិតប្រចាំសាធារណរដ្ឋប្រជាមានិតចិន CUGB។

- **សកម្មភាពការងារនៅក្រៅប្រទេស៖**
  - បានអញ្ជើញបំពេញការងារនៅក្រៅប្រទេស **ចំនួន៤លើក** រួមមាន៖

១/ អញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជា បំពេញទស្សនកិច្ច នៅសាធារណរដ្ឋសង្គមនិយមវៀតណាម និងបានបន្តអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាប្រើភាសាបារាំង (APF) នៅខេត្តកាន់ថឺនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

២/ អញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់សភាកម្ពុជា ចូលរួមមហាសន្និបាតសហភាពអន្តរសភា (IPU) លើកទី១៥០ និងកិច្ចប្រជុំពាក់ព័ន្ធ ក្រោមមូលបទ "សកម្មភាពសភា ដើម្បីការអភិវឌ្ឍសង្គម និងយុត្តិធម៌" នៅទីក្រុងតាស្កិននៃសាធារណរដ្ឋអ៊ូសបេគីស្ថាន។

៣/ អញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា បំពេញទស្សនកិច្ចការងារ នៅសាធារណរដ្ឋឥណ្ឌូណេស៊ី និងទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ និង

៤/ អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាកម្ពុជា ចូលរួមវេទិកាលើកទី៣ នៃកិច្ចសន្ទនាសភាត្បូង-ត្បូង (South-South Parliamentary Dialogue) ក្រោមប្រធានបទកិច្ចសន្ទនាអន្តរតំបន់ និងទ្វីប នៅបណ្តាប្រទេសភាគខាងត្បូង ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីដោះស្រាយបញ្ហាប្រឈមថ្មីៗ និងដើម្បីសម្រេចឱ្យបាននូវសន្តិភាព សន្តិសុខ ស្ថិរភាព និងការអភិវឌ្ឍរួម នៅព្រះរាជាណាចក្រម៉ារ៉ុក។

- **សកម្មភាពចូលរួមពិធីផ្សេងៗ៖** បានអញ្ជើញជាអធិបតីក្នុងពិធីពិសាអាហារការងារជាមួយភ្ញៀវជាតិ-អន្តរជាតិ ចំនួន៦លើក។

❖ **ឯកឧត្តមបណ្ឌិត ឆន់ ខន្សែនា អនុប្រធានទី២ព្រឹទ្ធសភា៖**

- **បដិសណ្ឋារកិច្ចភ្ញៀវជាតិ-អន្តរជាតិ៖** បានអនុញ្ញាតឱ្យភ្ញៀវជាតិ-អន្តរជាតិ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ **ចំនួន១២លើក** រួមមាន៖
  + **បដិសណ្ឋារកិច្ចភ្ញៀវជាតិ៖** បានអនុញ្ញាតឱ្យភ្ញៀវជាតិ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ចំនួន៤លើក៖
    ១/ គណៈប្រតិភូព្រឹទ្ធសភា ដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា។
    ២/ ក្រុមប្រឹក្សាអភិវឌ្ឍន៍ និងស្តារកសិកម្មនៅកម្ពុជា។
    ៣/ តំណាងក្រុមហ៊ុន Metfone និង
    ៤/ ប្រធានវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)។
  + **បដិសណ្ឋារកិច្ចភ្ញៀវអន្តរជាតិ៖** បានអនុញ្ញាតឱ្យភ្ញៀវអន្តរជាតិ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ចំនួន៨លើក៖
    ១/ ក្រុមហ៊ុនវិនិយោគជប៉ុន។
    ២/ អភិបាលក្រុង Kota ប្រទេសជប៉ុន។
    ៣/ គណៈប្រតិភូកូរ៉េនៃវិទ្យាស្ថានបច្ចេកវិទ្យា និងវិទ្យាសាស្ត្រ (DIST)។
    ៤/ **សាស្ត្រាចារ្យ ហ៊ីយុន ហុនលី** ប្រធាន THE 4TH WAY INSTITUTE និងជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យជាតិ Kangwon សាធារណរដ្ឋកូរ៉េ។
    ៥/ អគ្គនាយកផ្នែកទីផ្សារនៃក្រុមហ៊ុន SuRaLa Net។
    ៦/ ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ី។
    ៧/ អតីតនិស្សិតមកពីសាកលវិទ្យាល័យ Nagoya ប្រទេសជប៉ុន និង
    ៨/ **លោកស្រីបណ្ឌិត រិទ្ធី ឌី អាឌីពូទ្រី** ដែលកំពុងធ្វើការស្រាវជ្រាវ នៅសាកលវិទ្យាល័យ Jyvaskyla នៅប្រទេសហ្វាំងឡង់។
- **សកម្មភាពចូលរួមពិធីផ្សេងៗ៖** បានអញ្ជើញជាអធិបតីក្នុងពិធីពិសាអាហារការងារជាមួយភ្ញៀវជាតិ-អន្តរជាតិ ចំនួន២លើក។

❖ **សមាជិក សមាជិកាព្រឹទ្ធសភាបាន៖**

- អញ្ជើញចូលរួមវេទិកា សិក្ខាសាលា ទស្សនកិច្ច និងកិច្ចប្រជុំអន្តរជាតិនានា **ចំនួន២៦លើក** រួមមាន៖
  ១/ កិច្ចប្រជុំត្រៀមរៀបចំមហាសន្និបាតលើកទី១១ តំបន់អាស៊ី-ប៉ាស៊ីហ្វិកនៃសភាប្រើភាសាបារាំង តាមប្រព័ន្ធនិម្មិត នៅសាលប្រជុំពិសេសកណ្តាល វិមានព្រឹទ្ធសភា។
  ២/ កិច្ចប្រជុំត្រៀមរៀបចំការប្រជុំប្រចាំឆ្នាំរបស់ក្រុមអ្នកនយោបាយអាយប៉ា (AIPA) លើកទី១៦ នៅវិមានរដ្ឋសភា។

៣/ កិច្ចប្រជុំចង្អៀតត្រៀមរៀបចំកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ ឆ្នាំ២០២៦ នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

៤/ កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៃបណ្តាញហ្វ្រង់កូហ្វូនសីលធម៌ និងក្រមសីលធម៌សមាជិកសភា ដើម្បីពិភាក្សាកម្មវិធី និងប្រធានបទសម្រាប់មហាសន្និបាតប្រចាំឆ្នាំតាមប្រព័ន្ធនិម្មិត នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។

៥/ ចូលរួមកម្មវិធីខួបលើកទី៧៥ នៃការបង្កើតទំនាក់ទំនងទ្វេភាគីរវាងសហរដ្ឋអាមេរិក និងព្រះរាជាណាចក្រកម្ពុជា នៅសារមន្ទីរជាតិកម្ពុជា រាជធានីភ្នំពេញ។

៦/ ចូលរួមជាកិត្តិយសក្នុងកម្មវិធីខួបលើកទី៦ របស់វិទ្យាស្ថានចក្ខុវិស័យអាស៊ី ក្រោមប្រធានបទ "គោលនយោបាយការបរទេសកម្ពុជាក្នុងយុគសម័យថ្មី" និងកម្មវិធីពិសេសស្តីពី ការដាក់សម្ពោធសៀវភៅ "អាស៊ាន និងទំនួលខុសត្រូវក្នុងការការពារ ASEAN and Responsibility to Protect (R2P)៖ ទំនាក់ទំនងដែលមានភាពស្រពិចស្រពិល" នៅសណ្ឋាគារ ហៃយ៉ាត់រីជិនស៊ី រាជធានីភ្នំពេញ។

៧/ កិច្ចប្រជុំពិភាក្សាការងារជាមួយឯកអគ្គរដ្ឋទូតនៃសហព័ន្ធរុស្ស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា ស្តីពី "កិច្ចការទូទៅពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការអន្តរសភារវាងប្រទេសទាំងពីរ" នៅសាលប្រជុំគណៈកម្មការទី៥ វិមានព្រឹទ្ធសភា។

៨/ ចូលរួមកម្មវិធីសមាជអេកូឡូស៊ីអន្តរជាតិនេវស្គីលើកទី១១ Programme of the Eleventhe Nevsky Ecological Congress តាមប្រព័ន្ធនិម្មិត ពីទីក្រុង Saint Petersburg សហព័ន្ធរុស្ស៊ី ក្រោមប្រធានបទ "អេកូឡូស៊ីនៃតថភាពថ្មី៖ បញ្ហាប្រឈម និងឱកាស" នៅសាលពិសេសកណ្តាល វិមានព្រឹទ្ធសភា។

៩/ ពិធីសម្តែងក្បាច់រាំអន្តរជាតិរបស់និស្សិតសាកលវិទ្យាល័យ BYU (Brigham Young University)សហរដ្ឋអាមេរិក នៅសាលមហោស្រព និងពិព័រណ៍កោះពេជ្រ។

១០/ ចូលរួមក្នុងពិធីជួបជុំអតីតនិស្សិតយោធាកម្ពុជា-អូស្ត្រាលី ឆ្នាំ២០២៥ នៅសណ្ឋាគារ Raffles Le Royal រាជធានីភ្នំពេញ។

១១/ កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំបន់អាស៊ីស្តីពី កិច្ចការនយោបាយ នៅទីក្រុងបាកដាដ ប្រទេសអ៊ីរ៉ាក់។

១២/ កិច្ចប្រជុំផ្សព្វផ្សាយ តម្រង់ទិសដល់និស្សិតអាហារូបករណ៍មូលនិធិមុទិតា និងចែករំលែកបទពិសោធន៍អំពីការត្រៀមខ្លួនទៅសិក្សាបន្ត នៅសាធារណរដ្ឋប្រជាមានិតចិន។

១៣/ ទស្សនកិច្ចសិក្សា នៅរដ្ឋធានីហាណូយនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

១៤/ កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាប្រើភាសាបារាំង(APF) នៅខេត្តកាន់ថឺនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

១៥/ កិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិ និងមហាសន្និបាត លើកទី១៥ នៃសភាតំបន់អាស៊ី (APA) នៅទីក្រុងបាគូ ប្រទេសអាស៊ែបៃហ្សង់។

១៦/ កិច្ចប្រជុំគណៈកម្មការកិច្ចការសភានៃសភាប្រើភាសាបារាំង (APF) នៅទីក្រុងវៀងចន្ទន៍នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

១៧/ កិច្ចប្រជុំអនុគណៈកម្មការបណ្តាញសមាជិកសភាប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតសកលនៃសភាប្រើភាសាបារាំង (APF) តាមប្រព័ន្ធនិម្មិត នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។

១៨/ កិច្ចប្រជុំគណៈកម្មាធិការត្រួតពិនិត្យ និងតាមដាននៅក្នុងគណៈកម្មការនយោបាយ (APF) នៅសាធារណរដ្ឋសេណេហ្កាល់។

១៩/ ចូលរួមកិច្ចប្រជុំផ្ទៃក្នុងរបស់សភាសមាជិកអាយប៉ា មុននឹងចូលរួមកិច្ចប្រជុំរួមគ្នារវាងថ្នាក់ដឹកនាំអាយប៉ា និងប្រមុខដឹកនាំអាស៊ាន ដើម្បីពិភាក្សាលើសេចក្តីព្រាងសាររបស់អាយប៉ា ដែលឆ្លុះបញ្ចាំងលើប្រធានបទបរិយាបន្នភាព និងនិរន្តរភាពនៃកិច្ចប្រជុំកំពូលអាស៊ានលើកទី៤៦ នៅវិមានរដ្ឋសភានៃសហព័ន្ធម៉ាឡេស៊ី។

២០/ មហាសន្និបាតពិភពលោកឆ្នាំ២០២៥ នៃសហព័ន្ធសន្តិភាពពិភពលោក៖ ការបង្កើតយុគសម័យថ្មីនៃសន្តិភាព និងវិបុលភាព នៅទីក្រុងសេអ៊ូលនៃសាធារណរដ្ឋកូរ៉េ។

២១/ មហាសន្និបាតគណៈមេធាវីនៃសាធារណរដ្ឋបារាំង និងធ្វើបទបង្ហាញសង្ខេបស្តីពីច្បាប់សាធារណរដ្ឋបារាំង និងក្រមរដ្ឋប្បវេណីរបស់កម្ពុជា នៅសាធារណរដ្ឋបារាំង។

២២/ ការតាំងពិព័រណ៍រូបថត ក្រោមប្រធានបទ "Tokyo Before/After" នៅសារមន្ទីរព្រះស្រីឦសានវរ្ម័ន។

២៣/ សន្និសីទអន្តរជាតិរៀបចំដោយក្រុមប្រឹក្សាសេរីនិយម និងប្រជាធិបតេយ្យអាស៊ី (CALD) នៅមហាវិទ្យាល័យ Miriam ទីក្រុង Quezon សាធារណរដ្ឋហ្វីលីពីន។

២៤/ សិក្ខាសាលាសហប្រតិបត្តិការអន្តរសភាថ្នាក់តំបន់ស្តីពី គោលនយោបាយអាកាសធាតុ នៅព្រះរាជាណាចក្រថៃ។

២៥/ សិក្ខាសាលាអន្តរជាតិ ក្រោមប្រធានបទ "ទស្សនវិស័យក្នុងតំបន់ស្តីពី ព័ត៌មានមិនពិត និងឥទ្ធិពលរបស់វា" នៅទីក្រុងព្រុចសែល ប្រទេសបែលហ្ស៊ិក និង

២៦/ កម្មវិធី Gala ដើម្បីផ្តល់អាហារូបករណ៍ ដល់យុវជនខ្មែរក្រីក្រ សម្រាប់ការសិក្សាចាប់ពីថ្នាក់បឋមសិក្សា រហូតដល់បរិញ្ញាបត្រ នៅសណ្ឋាគារ Raffles Le Royal។

- អញ្ជើញជួបសវនាការ សម្តែងការគួរសម និងពិភាក្សាការងារជាមួយភ្ញៀវជាតិ-អន្តរជាតិនានា **ចំនួន១៨លើក** រួមមាន៖

១/ **ឯកឧត្តម ហួត ហាក់** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ដើម្បីសហការរៀបចំកម្មវិធីប្រគំតន្ត្រីសប្បុរសធម៌កម្ពុជា-កូរ៉េ។

២/ **លោក ខៀវ កូឡា** អគ្គនាយករងទទួលបន្ទុកព័ត៌មាននៃទូរទស្សន៍ CNC។

៣/ **លោក ហ្វូជី តូរូ** ប្រធានសភាក្រុងកូតា និងអ្នកវិនិយោគទុន ជនជាតិជប៉ុន ចំនួន៧នាក់។

៤/ ក្រុមការងារនៃនាយកដ្ឋានអភិវឌ្ឍន៍វិទ្យាស្ថានលេខ២ របស់ក្រុមហ៊ុន DIST នៃសាធារណរដ្ឋកូរ៉េ ដើម្បីស្វែងរកដៃគូអភិវឌ្ឍន៍ទាក់ទងនឹងវិស័យកសិកម្ម កម្មវិធី (Smart Farm)។

៥/ **ឯកឧត្តម ឡូរ៉េន វីលី** ប្រធានគណៈកម្មាធិការគោលនយោបាយការបរទេសនៃក្រុមប្រឹក្សាជាតិនៃប្រទេសស្វីស។

៦/ **លោកស្រី អេនជេឡា កូរកូរេន** ឯកអគ្គរដ្ឋទូតអូស្ត្រាលី ប្រចាំសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា។

៧/ **ឯកឧត្តម ដារេក យីប** ឯកអគ្គរដ្ឋទូតអូស្ត្រាលី។

៨/ **ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី** ឯកអគ្គរាជទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា។

៩/ **លោក លី ជិន យូក** អគ្គនាយកក្រុមហ៊ុន Cropmate Fertilizer Sdn.Bhd ដែលជាក្រុមហ៊ុនផលិតជីពាក់កណ្ដាលសរីរាង្គ និងជីគីមី។

១០/ **លោក វ៉ាង ហ្សី ហេង** អគ្គនាយកក្រុមហ៊ុន DIMENG GROUP។

១១/ **លោកស្រី អ៊ីស៊ូកូ អ៊ីសេគី** គណៈប្រតិភូក្រុមហ៊ុនជប៉ុន Nakanishi Kosan។

១២/ **លោក ប្រេត ហ័រតុន** គណៈប្រតិភូសមាជិកឧទ្ទកាល័យសមាជិកសភាអាមេរិក។

១៣/ **លោកស្រី កូហ្គា អាស៊ីកា** លេខាទី៣ស្ថានទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា។

១៤/ **លោក ភីធូ ឡាញ់ លោកស្រី ស៊ីសាវ៉ា ទ្រីផាមស៊ាប** និង**លោកស្រី បេនច្រេសស៊ីរីវឌ្ឍនាប៉ានុម** តំណាងក្រុមហ៊ុន Price Waterhouse Coopers។

១៥/ **ឯកឧត្តម យ៉ុងចាង មីន** តំណាងមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ។

១៦/ ក្រុមអ្នកវិនិយោគជនជាតិជប៉ុន។

១៧/ **លោកជំទាវ មីលេណា ការីដាជ ហ្សាលឌីវើ ភីជ្រា** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋគុយបា ប្រចាំព្រះរាជាណាចក្រកម្ពុជា និង

១៨/ **កញ្ញា សាវ៉ា វីលសាវ៉ា** ប្រធានពាណិជ្ជកម្មកាណាដា។

- **សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖**

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភាបាន៖

▪ អញ្ជើញចូលរួមអមដំណើរ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភាដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជា បំពេញទស្សនកិច្ចផ្លូវការនៅក្រៅប្រទេស ចំនួន៤លើក រួមមាន៖ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋឥណ្ឌូណេស៊ី និងសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ ដោយក្នុងឱកាសទស្សនកិច្ចនោះ **ឯកឧត្តមអគ្គលេខាធិការ** បានអញ្ជើញចូលរួមអម **សម្ដេចតេជោ** ក្នុងជំនួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំ និងភ្ញៀវបរទេស ចំនួន១៦លើក។

- អញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ក្នុងពិធីជូនសារតាំង ជំនួបសម្តែងការគួរសម និងពិភាក្សាការងារ ជាមួយភ្ញៀវអន្តរជាតិនានា នៅវិមានព្រឹទ្ធសភា វិមាន៧មករា និងវិមានសន្តិភាព ចំនួន២៣លើក។
- អញ្ជើញចូលរួមអម **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា ពិសាអាហារពេលព្រឹកការងារជាមួយ **លោកជំទាវ** Bridgette L.Walker ភារធារីស្តីទីនៃស្ថានទូតអាមេរិកប្រចាំព្រះរាជាណាចក្រកម្ពុជា នៅសាលពិសេសIII វិមានព្រឹទ្ធសភា។
- អញ្ជើញបំពេញទស្សនកិច្ចសិក្សានៅរដ្ឋសភា និងព្រឹទ្ធសភានៃសាធារណរដ្ឋបារាំង ដោយក្នុងឱកាសទស្សនកិច្ចនោះ **ឯកឧត្តមអគ្គលេខាធិការ** បានអញ្ជើញជួបពិភាក្សាការងារជាមួយសមាជិក សមាជិកាព្រឹទ្ធសភាបារាំង ចំនួន៣រូប។
- អនុញ្ញាតឱ្យភ្ញៀវអន្តរជាតិចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅបន្ទប់ប្រជុំឯកឧត្តមអគ្គលេខាធិការ វិមានព្រឹទ្ធសភា ចំនួន៦លើក និង
- អញ្ជើញដឹកនាំ និងចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ នៅរាជធានីភ្នំពេញ ចំនួន៧លើក។

❖ **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភាបាន៖

- អញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ក្នុងជំនួបសម្តែងការគួរសមជាមួយ **ឯកឧត្តម ឯក ណាត ជាកាល់** អគ្គលេខាធិការនៃសន្និសីទប្រធានសភានៃអន្តរសភា (ISC) នៅវិមានព្រឹទ្ធសភា។
- អញ្ជើញចូលរួមអម **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា ក្នុងជំនួបសម្តែងការគួរសមជាមួយសមាគមនិស្សិតប្រចាំសាធារណរដ្ឋប្រជាមានិតចិននៃសាកលវិទ្យាល័យ CUGB និង
- អញ្ជើញដឹកនាំគណៈប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តមបណ្ឌិត ម៉ាន់ម៉ូហាន់ សិញ** អតីតនាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋឥណ្ឌា នៅស្ថានទូតឥណ្ឌា រាជធានីភ្នំពេញ។

❖ **ឯកឧត្តម ខេង សិទ្ធិគុណ** និង**ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមអម **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** ប្រធានស្តីទីព្រឹទ្ធសភា ចូលរួមគោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តមនាយឧត្តមសេនីយ៍ ខាំតៃ ស៊ីផាន់ដន** អតីតនាយករដ្ឋមន្ត្រី និងជាប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

❖ បានសហការ និងទាក់ទងជាមួយស្ថានទូតចិន មូលនិធិចិនដើម្បីអភិវឌ្ឍន៍ជនបទ(CFRD) មជ្ឈមណ្ឌលសភាអាស៊ី(PCAsia) មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់កម្ពុជា មជ្ឈមណ្ឌលស្រាវជ្រាវច្បាប់ចិន-អាស៊ាន(CALRC) សមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា(CADT) បណ្ណសារដ្ឋានជាតិ បណ្ណាល័យ ក្រសួងស្ថាប័ន និងដៃគូអភិវឌ្ឍន៍ក្នុង-ក្រៅប្រទេសនានា ដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការអន្តរជាតិ ការស្នើសុំអាហារូបករណ៍ រៀបចំវគ្គបណ្តុះបណ្តាល ការស្វែងរកភ្ញៀវគេជំនួយ ព្រមទាំងការរៀបចំកម្មវិធីផ្សេងៗ។

## ៥-មុខងារអភិវឌ្ឍន៍ស្ថាប័ន

### ៥.១-សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភាបាន៖
  - អញ្ជើញទទួលជួប និងដឹកនាំកិច្ចប្រជុំជាមួយ **ឯកឧត្តមបណ្ឌិត ចន ណារិទ្ធ** អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីពិភាក្សាការងារពាក់ព័ន្ធនឹងការកែទម្រង់របបសោធនសាធារណៈ នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
  - អញ្ជើញជាអធិបតីដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែមករា-ខែមិថុនា ឆ្នាំ២០២៥ ព្រមទាំងទិសដៅការងារបន្ត ចំនួន៦លើក។
  - អញ្ជើញដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាវិន័យនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដោយមានការចូលរួមពីថ្នាក់ដឹកនាំក្រុមប្រឹក្សាវិន័យនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅបន្ទប់ប្រជុំឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា។
  - អញ្ជើញដឹកនាំកិច្ចប្រជុំក្រុមការងារវាយតម្លៃដំឡើងថ្នាក់មន្ត្រីរាជការ ដោយមានការចូលរួមពីថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅបន្ទប់ប្រជុំឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា និង
  - អញ្ជើញដឹកនាំកិច្ចប្រជុំផ្ទៃក្នុងជាមួយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅបន្ទប់ប្រជុំឯកឧត្តមអគ្គលេខាធិការ វិមានព្រឹទ្ធសភា។
- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា **ឯកឧត្តម ខេង សិទ្ធិគុណ** និង**ឯកឧត្តម អោក ប៉ូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភាបាន៖
  - អញ្ជើញចូលរួមកិច្ចប្រជុំពិនិត្យវឌ្ឍនភាពដំណើរការសាងសង់អគារថ្មីនៃព្រឹទ្ធសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងជាប្រធានគណៈកម្មការសាងសង់អគារថ្មីនៃព្រឹទ្ធសភា នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង
  - អញ្ជើញអមដំណើរ **ឯកឧត្តម ប្រាក់ សុខុន** ប្រធានគណៈកម្មការសាងសង់អគារថ្មីនៃព្រឹទ្ធសភាត្រួតពិនិត្យមើលវឌ្ឍនភាពនៃដំណើរការសាងសង់អគារថ្មីនៃព្រឹទ្ធសភា ដោយផ្ទាល់ នៅវិមានព្រឹទ្ធសភា។

### ៥.២-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ៖

- បានរៀបចំសេចក្តីព្រាងគម្រោងផែនការថវិកាឆ្នាំ២០២៦ របស់ព្រឹទ្ធសភា ដើម្បីប្រជុំពិភាក្សា និងឆ្លងយោបល់ថ្នាក់ដឹកនាំ។
- បានធ្វើរបាយការណ៍ទូទាត់ថវិកាព្រឹទ្ធសភា ប្រចាំឆមាសទី១ ឆ្នាំ២០២៥ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា។
- បានបោះពុម្ពផ្សាយអាណត្តិសម្រាប់ត្រីមាសទី១ ទី២ និងទី៣ ជំពូក៦០ ៦១ ៦២ និង៦៤ បញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

- បានផ្សាយអាណត្តិថ្លៃប្រើប្រាស់ទឹក អគ្គិសនី និងអ៊ីនធឺណែត បញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- បានស្នើសុំ និងទូទាត់ថវិកាបុរេប្រទាន ចំនួន៤បុរេប្រទាន សម្រាប់គណៈប្រតិភូជាន់ខ្ពស់ និងគណៈប្រតិភូព្រឹទ្ធសភា បំពេញបេសកកម្ម និងទស្សនកិច្ចផ្លូវការនៅក្រៅប្រទេស ព្រមទាំងការទិញរថយន្តជូនថ្នាក់ដឹកនាំព្រឹទ្ធសភា។
- បានស្នើសុំបុរេប្រទានថវិកា និងឥណទានថវិកាបន្ថែម ចំនួន២បុរេប្រទាន សម្រាប់ចំណាយរៀបចំបុណ្យសពជូនសមាជិកព្រឹទ្ធសភា ចំនួន២រូប និងបេសកកម្មក្រៅប្រទេសរបស់ប្រតិភូព្រឹទ្ធសភា។
- បានស្នើសុំឥណទានបន្ថែមលើអនុគណនី (៦៤០៥៤) សម្រាប់ចំណាយបើកផ្តល់ជូននិវត្តជនជាសមាជិក សមាជិកាព្រឹទ្ធសភា សម្រាប់ឆ្នាំ២០២៥ និងអនុគណនី (៦៤០១៦) សម្រាប់ចំណាយបើកផ្តល់ជូនទីប្រឹក្សា នាយក នាយករង ជំនួយការ និងសមាជិក សមាជិកាខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភាសម្រាប់ឆមាសទី២ ឆ្នាំ២០២៥។
- បានបង្វែរប្រាក់បៀវត្ស ប្រាក់បំណាច់ ប្រចាំខែមករា-ខែមិថុនា ឆ្នាំ២០២៥ ប្រាក់ឧបត្ថម្ភបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិក សមាជិកាព្រឹទ្ធសភា សមាជិក សមាជិកាព្រឹទ្ធសភាចូលនិវត្តន៍ និងថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និវត្តជន មន្ត្រីនគរបាលសន្តិសុខ ជំនួយការផ្ទាល់ អ្នកបើកបររថយន្ត តាមរយៈប្រព័ន្ធធនាគារអេស៊ីលីដា។
- បានបង្វែរប្រាក់ប្រមុខរដ្ឋស្តីទី ប្រាក់សង្គមកិច្ចថ្នាក់ដឹកនាំព្រឹទ្ធសភា ប្រាក់ឧបត្ថម្ភពិនិត្យ និងព្យាបាលជំងឺមន្ត្រីរាជការ ប្រាក់៧%នៃប្រាក់បៀវត្សមន្ត្រីរាជការបង់ចូលបេឡាសោធននិវត្តន៍ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងប្រាក់ឧបត្ថម្ភមូលនិធិសង្គមកិច្ចមន្ត្រីរាជការប្រចាំខែមករា-ខែមិថុនា ឆ្នាំ២០២៥ តាមរយៈប្រព័ន្ធធនាគារអេស៊ីលីដា។
- បានបង្វែរប្រាក់ភាគទានជូនអង្គភាពបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) របស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំត្រីមាសទី១ និងត្រីមាសទី២ ឆ្នាំ២០២៥។
- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៣៥៩សំណើ ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗ ចំនួន៤៧០សំណើ។
- បានដោះស្រាយសំណើផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារៈអនាម័យ សម្ភារៈការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ ចំនួន១៩៥សំណើ។
- បានថតចម្លងឯកសារ ចំនួន២៥,៨៣៤ច្បាប់ និងចងក្រងធ្វើជាសៀវភៅ ចំនួន២០ក្បាល ប្រើប្រាស់ក្រដាសអស់ ចំនួន២៤៦,៩៣៤សន្លឹក។
- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្ម នៅតាមបណ្តាភូមិភាគទាំង៨ ចំនួន ៤៥៤លើក ស្មើនឹង១,៣៨៤នាក់។

- បានរៀបចំបោសសម្អាត តុបតែងលម្អសាល ព្រមទាំងផ្តល់សេវាបម្រើភេសជ្ជៈ ក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន១៣៧លើក។
- បានទទួលលិខិតចូល ចំនួន៤,៤១៤ច្បាប់ និងបញ្ជូនលិខិតចេញទៅក្រសួង ស្ថាប័នពាក់ព័ន្ធនានា ចំនួន៣,៨០២ច្បាប់។
- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន២០២ច្បាប់ ស្មើនឹង៩០៦នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិក សមាជិកាព្រឹទ្ធសភា ចំនួន៤៧ច្បាប់។
- បានចុះសួរសុខទុក្ខមន្ត្រីរាជការលំហែមាតុភាព មានជំងឺ គ្រោះថ្នាក់ចរាចរណ៍ និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ចំនួន៤៧លើក។
- ការងារកែលម្អសួនច្បារ និងបរិស្ថានក្នុងបរិវេណព្រឹទ្ធសភា រួមមាន៖
  - បានកាត់តម្រឹមស្មៅ មែកឈើ និងផ្កានានា ចំនួន១០៣លើក។
  - បានតាំងលម្អដើមសុភមង្គល ផ្កាស្បៃរឿង ផ្កាមិថុនា ផ្កាអ័រគីដេ និងផ្កាផាវ ចំនួន២៦៥គុម្ព/ផើង។
  - បានដាំដើមជ្រៃ ដើមឫស្សី ដើមម្លូពណ៌ និងដើមផ្លីសេ ចំនួន៤២០គុម្ព។
  - បានកែលម្អសួនច្បារនៅមុខអគារក្រហមជុំវិញជងទង់ជាតិ សួនច្បារជុំវិញរទេះគោ និងនៅមុខអគារក្រហម ចំនួន៤៨០គុម្ព។
  - បានសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីដកដើមឈើនៅច្រកចូល P1 ជាប់អគារសាងសង់ថ្មី របស់ព្រឹទ្ធសភា។
  - បានបាញ់ថ្នាំសម្លាប់សត្វល្អិត និងស្មៅតាមសួនច្បារនានា និង
  - បានសម្អាតអនាម័យតាមអគារធ្វើការ និងក្នុងបរិវេណព្រឹទ្ធសភាជាប្រចាំ។
- បានសម្របសម្រួលការរៀបចំគូរប្លង់រចនាទេសភាពសួនច្បារស្រះត្រី និងសួនច្បារសាលពិសេសវិមានព្រឹទ្ធសភា។
- បានធ្វើបញ្ជីស្ថិតិមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំឆមាសទី១ មានចំនួន៧១៥នាក់ (ស្រី២៨៩នាក់) ក្នុងនោះ
  - មន្ត្រីរាជការស្ថិតក្នុងភាពទំនេរដោយគ្មានបៀវត្ស ចំនួន១២នាក់។
  - មន្ត្រីរាជការស្ថិតនៅក្រៅក្របខ័ណ្ឌដើម ចំនួន៥នាក់។
  - មន្ត្រីរាជការមានមុខតំណែងគ្រប់គ្រង ចំនួន៤៩២នាក់ និង
  - បុគ្គលិកជាប់កិច្ចសន្យា ចំនួន៨៧នាក់ (ស្រី៣៥នាក់)។
- បានធ្វើសេចក្តីសម្រេច ចំនួន៣៧ច្បាប់ និងលិខិតបង្គាប់ការ ចំនួន១៣ច្បាប់។
- បានធ្វើតារាងបញ្ជាក់ប្រាក់បៀវត្ស ប្រាក់បំណាច់ផ្សេងៗ លិខិតផ្តត់ផ្តង់ និងវិញ្ញាបនបត្របញ្ជាក់រយៈពេលបំពេញការងាររដ្ឋ ចំនួន៣៣ច្បាប់។
- បានធ្វើបញ្ជីរាយនាមមន្ត្រីរាជការស្នើសុំប្រាក់វិភាជន៍គ្រួសារ (ប្រពន្ធ-កូន) ប្រចាំខែមករា-ខែមិថុនា និងប្រចាំឆមាសទី១ ឆ្នាំ២០២៥។

- បានសហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រៀបចំធ្វើបច្ចុប្បន្នភាពប័ណ្ណសមាជិកបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) ជូនមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។
- បានរៀបចំធ្វើបច្ចុប្បន្នភាពព័ត៌មានជីវប្រវត្តិមន្ត្រីរាជការគ្រប់ខ័ណ្ឌនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានធ្វើបច្ចុប្បន្នភាព និងព្រាងនូវកម្រងសំណួរសម្រាប់សិក្សាពីតម្រូវការជំនាញ តាម Google Form ដើម្បីត្រៀមធ្វើផែនការបណ្តុះបណ្តាលឆ្នាំ២០២៦។
- បានផ្សព្វផ្សាយរបាយការណ៍វាយតម្លៃសារពើភ័ណ្ឌជំនាញ និងតម្រូវការបណ្តុះបណ្តាលឆ្នាំ២០២៥ និងបញ្ជីវគ្គបណ្តុះបណ្តាលជូនគ្រប់នាយកដ្ឋាន អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានទទួលអាហារូបករណ៍ពីសាកលវិទ្យាល័យអាស៊ីអឺរ៉ុប៥០% សម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ចំនួន៥កន្លែង។
- បានរៀបចំវគ្គបណ្តុះបណ្តាលក្នុងស្ថាប័នព្រឹទ្ធសភា ចំនួន៣វគ្គ មានសិក្ខាកាម ចំនួន៤៣នាក់ រួមមាន៖
  - វគ្គមូលដ្ឋានគ្រឹះភាសាចិន (បន្តជំហាន២)។
  - វគ្គភាសាចិនថ្នាក់បឋម (បន្តជំហាន៩) និង
  - វគ្គភាសាចិនថ្នាក់មធ្យម (បន្តជំហាន៩)។
- បានបញ្ជូនមន្ត្រីរាជការចូលរួមវគ្គបណ្តុះបណ្តាលនៅក្រៅស្ថាប័នព្រឹទ្ធសភា ចំនួន៤វគ្គ មានសិក្ខាកាមចំនួន១៥នាក់ រួមមាន៖
  - វគ្គវិក្រឹតការជាន់ខ្ពស់ឆ្នាំ២០២៥ នៅសាលាភូមិន្ទរដ្ឋបាល។
  - វគ្គការទូតសភា (ជំហានទី៧) នៅមជ្ឈមណ្ឌលសភាអាស៊ី។
  - វគ្គគោលនយោបាយប្រាស្រ័យទាក់ទង នៅវិមានរដ្ឋសភា និង
  - វគ្គភាសាចិនកម្រិត HSK2 នៅវិទ្យាស្ថានការទូត និងទំនាក់ទំនងអន្តរជាតិ។
- បានបញ្ជូនមន្ត្រីរាជការ ចំនួន២រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការវិភាគសារពើពន្ធ និរន្តរភាពហិរញ្ញវត្ថុ និងការគណនាគោលនយោបាយ នៅសាធារណរដ្ឋកូរ៉េ។
- ការងារសាងសង់សំណង់ថ្មីៗ ជួសជុលកែលម្អអគារ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ក្នុងបរិវេណវិមានព្រឹទ្ធសភា រួមមាន៖
  - បានរៀបចំបន្ទប់ការិយាល័យជូន **ឯកឧត្តម សាន សាង** ទីប្រឹក្សាសម្តេចតេជោប្រធានព្រឹទ្ធសភា។
  - បានបាំងបន្ទប់កញ្ចក់ជញ្ជាំងស្មាតបត បិទក្រដាសជញ្ជាំង ជួសជុលទ្វារឈើក្បាច់ នៅខុទ្ទកាល័យសម្តេចតេជោប្រធានព្រឹទ្ធសភា និងបានរៀបចំបន្ទប់ការិយាល័យក្រុមការងារព័ត៌មាន សម្តេចតេជោប្រធានព្រឹទ្ធសភា និងក្រុមការងារបច្ចេកទេសនៃទូរទស្សន៍ជាតិកម្ពុជានៅក្រោមអគារក្រហម និងរៀបចំជូនមេបញ្ជាការអង្គរក្សការពារព្រឹទ្ធសភា។
  - បានធ្វើ Logo ប្រមុខរដ្ឋស្តីទី Logo សមាជរដ្ឋសភា និងព្រឹទ្ធសភា និងបំពាក់នាឡិកាអគ្គិសនីព្រមទាំងជួសជុលចង្ករទឹកមុខជណ្តើរយន្ត នៅអគារក្រហមព្រឹទ្ធសភា។
  - បានខាត់ លាបផ្លូវដើរ នៅខាងមុខសាលប្រជុំពេញអង្គព្រឹទ្ធសភា។

- បានជួសជុលដំបូល ពិដាន ខាត់លាបជញ្ជាំង និងប្តូរអូតូធំទ្វារអាលុយមីញ៉ូម ក្ដារ M.C និងខាន់បន្ទប់ទឹកបុរស នៅសាលប្រជុំពេញអង្គ សាលពិសេស៣ សាលពិសេសក្រោម សាលសិក្ខាសាលាខាងជើង និងនាយកដ្ឋានស្រាវជ្រាវកិច្ចការអន្តរជាតិ។
- បានជួសជុលកែលម្អផ្នែកខាងលើដំបូលឃ្លាំង និងបន្ទប់ទឹក នៅខាងក្រោយសាលពិសេសលើ។
- បានផ្លាស់ប្តូរការ៉ូបាត រៀបការ៉ូថ្មី នៅបន្ទប់ការិយាល័យសមាជិកព្រឹទ្ធសភា សាលប្រជុំ និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានដំឡើងសំណាញ់តាមទទឹក សម្អាតទទឹក ដំបូល ខាត់ លាបថ្នាំពិដាន នៅនាយកដ្ឋានរដ្ឋបាល សាលប្រជុំ និងអគារ D.E.F។
- បានធ្វើស្លាកឈ្មោះថ្មី នៅបន្ទប់សមាជិកព្រឹទ្ធសភា និងបានប្តូរហ្វុងអក្សរ Background ឈ្មោះរបស់គណៈកម្មការ នៅបន្ទប់ប្រជុំគណៈកម្មការទី១ និងទី៤ព្រឹទ្ធសភា។
- បានក្រាលថ្មម៉ាប នៅអគារក្រហម មុខសាលសិក្ខាសាលាខាងជើង និងក្រោមដើមជ្រៃជាប់ចំណតរថយន្ត។
- បានជួសជុលម៉ូទ័រទ្វារ និងប្តូរតេឡេម៉ូទ័រថ្មី នៅច្រកចេញ-ចូល P1។
- បានបាញ់ថ្នាំដែកសង្កត់ព្រំ កងព្រំ នៅអគារក្រហម និងសាលពិសេស ចំនួន១៨៦ដើម។
- បានប្តូរខ្សែចងដងទង់ជាតិនៅមុខអគារក្រហម។
- បានបំពាក់កញ្ចក់សុវត្ថិភាពផ្លូវកែង និងស្លាកសញ្ញាបន្ថយល្បឿន ចំនួន៧ស្លាក។
- បានសហការជាមួយអគ្គិសនីកម្ពុជា លើកត្រង់ស្វូទូសុវត្ថិភាព និងចាក់សាបឱ្យបានខ្ពស់ និង
- បានសហការជាមួយអង្គភាពលូទឹក នៃមន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានីភ្នំពេញ ដើម្បីបូមស្អារប្រព័ន្ធលូ។

- បានជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធអគារ បណ្ដាញទឹក បណ្ដាញអគ្គិសនី ត្រួតពិនិត្យជណ្ដើរយន្ត កំចាត់សត្វកណ្ដៀរ រៀបចំ និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារិម ប្រមូលសម្ភារៈខូច បិទលេខកូដសម្ភារៈសារពើភ័ណ្ឌ និងបំពាក់សម្ភារៈការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀតក្នុងបរិវេណព្រឹទ្ធសភា ចំនួន៨៤៨គ្រឿង/លើក។
- បានស្រាវជ្រាវ និងរៀបចំចងក្រងសៀវភៅអំពីការវិវឌ្ឍនៃការប្រើប្រាស់អគារមួយចំនួន នៅវិមានព្រឹទ្ធសភា។
- បានសម្របសម្រួលការងារការដ្ឋាន និងបានរៀបចំរបាយការណ៍វឌ្ឍនភាពការងារសាងសង់អគារថ្មីនៃព្រឹទ្ធសភា រៀងរាល់ ២សប្តាហ៍ម្តង គោរពជូនថ្នាក់ដឹកនាំព្រឹទ្ធសភា។
- បានរៀបចំបែបបទជម្រះបញ្ជីអគារចាស់ដើម្បីយកទីតាំងសម្រាប់សាងសង់អគារថ្មីនៃព្រឹទ្ធសភា ចំនួន៣អគារ។
- បានរៀបចំឯកសារស្នើសុំជម្រះបញ្ជីរថយន្តព្រឹទ្ធសភា និងរៀបចំបែបបទឯកសារស្នើសុំគោលការណ៍ប្រគល់រថយន្តជូនអតីតប្រធានគណៈកម្មការ ចំនួន៧គ្រឿង។

- បានសហការ និងទាក់ទងធ្វើស្លាកលេខរថយន្ត ម៉ូតូ ជូនសមាជិកព្រឹទ្ធសភា និងខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា។
- បានរៀបចំចងក្រងសៀវភៅបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ឆ្នាំគោល (ឆ្នាំ២០២៤) របស់ព្រឹទ្ធសភា ចំនួន១៨ក្បាល។
- បានរៀបចំបញ្ចូលទិន្នន័យទ្រព្យសម្បត្តិរដ្ឋរបស់ព្រឹទ្ធសភា នៅក្នុងប្រព័ន្ធ SARMIS។
- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា ប្រចាំខែមករា-ខែមិថុនា និងប្រចាំឆមាសទី១ ឆ្នាំ២០២៥ ទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា ចំនួន៧លើក។
- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមករា-ខែមិថុនា និងប្រចាំឆមាសទី១ ឆ្នាំ២០២៥ ចំនួន១៤លើក ព្រមទាំងបានផ្សព្វផ្សាយលើគេហទំព័រព្រឹទ្ធសភា និងផ្ញើជូនក្រសួង ស្ថាប័នពាក់ព័ន្ធនានា និង
- បានធ្វើបទបង្ហាញ និងរបាយការណ៍ស្តីពី ការប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមករា-ខែមិថុនា ឆ្នាំ២០២៥ ចំនួន១២លើក។

## ៥.៣-ការងារសេវាច្បាប់៖

- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច ប្រកាស សារាចរណែនាំ របាយការណ៍ សេចក្តីជូនដំណឹង និងលិខិតផ្សេងៗ ចំនួន១០៣ច្បាប់ ពីក្រសួង និងស្ថាប័ននានា។
- បានទទួលសេចក្តីព្រាងច្បាប់ពីទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋសភា ចំនួន២៨ច្បាប់ ព្រមទាំងបានថ្វាយ និងចែកគ្រប់សមាជិក សមាជិកាព្រឹទ្ធសភា។
- បានរៀបចំឯកសារជំនួយស្មារតីក្នុងកិច្ចដំណើរការនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា សម័យប្រជុំព្រឹទ្ធសភា និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចំនួន ១២លើក។
- បានរៀបចំឯកសារជំនួយស្មារតីជូនលេខាធិការសម័យប្រជុំព្រឹទ្ធសភា នីតិកាលទី៥ ចំនួន៥លើក។
- បានរៀបចំឯកសារជំនួយស្មារតីជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា រាយការណ៍ជូនអង្គប្រជុំ ចំនួន៩លើក។
- បានរៀបចំនីតិវិធីបោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការទី៤ និងគណៈកម្មការទី៨ ព្រឹទ្ធសភា នីតិកាលទី៥។
- បានធ្វើកំណត់ហេតុពិស្តារ និងកំណត់ហេតុសង្ខេបនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា សម័យប្រជុំព្រឹទ្ធសភា ប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ និងកិច្ចប្រជុំគណៈកម្មការពិសេស ចំនួន២២លើក។
- បានប្រមូលផ្តុំចងក្រងឯកសារ លិខិតបទដ្ឋាននានា និងបោះពុម្ពសៀវភៅស្តីពី៖
  - បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។
  - កំណត់ហេតុពិស្តារ និងសង្ខេបនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំព្រឹទ្ធសភា នីតិកាលទី៥ (ឆ្នាំ២០២៤)។

- សេចក្តីសម្រេចនានារបស់ព្រឹទ្ធសភា នីតិកាលទី៥។
- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។
- ច្បាប់លក្ខន្តិកៈសមាជិកព្រឹទ្ធសភា និង
- ច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា។

- បានធ្វើបច្ចុប្បន្នភាព ប្រមូលផ្តុំចងក្រងឯកសារនានា រួមមាន៖
  - សម្រង់សង្ខេបសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ ដែលព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ តាមនីតិកាលនីមួយៗ។
  - សម្រង់លទ្ធផលសង្ខេបនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំព្រឹទ្ធសភា នីតិកាលទី៥។
  - បញ្ជីដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំព្រឹទ្ធសភា នីតិកាលទី៥ និង
  - បញ្ជីសេចក្តីព្រាងច្បាប់ ដែលព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ តាមនីតិកាលនីមួយៗ។
- បានបូកសរុបសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ដែលព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ ក្នុងឆ្នាំ២០២៤ និងឆ្នាំ២០២៥។
- បានទទួល និងប្រគល់សៀវភៅច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥ ភាគ១ ភាគ២ និងភាគ៣ ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងអង្គភាពពាក់ព័ន្ធ ចំនួន២៣៤ក្បាល។
- បានធ្វើបច្ចុប្បន្នភាពកម្មវិធីចុះបេសកកម្មរបស់គណៈកម្មការទាំង១០ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំព្រឹទ្ធសភា នីតិកាលទី៥ ចំនួន៣លើក។
- បានធ្វើតារាងទិន្នន័យ ស្ថិតិរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងចំនួនក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ (បច្ចុប្បន្នភាពខែតុលា ឆ្នាំ២០២៤)។
- បានផ្តល់សេវារដ្ឋបាល បច្ចេកទេស ព័ត៌មាន ពិធីការ ទំនាក់ទំនងការងារ ធ្វើរបាយការណ៍ រៀបចំកំណត់បង្ហាញ និងឯកសារផ្សេងៗ ជូនថ្នាក់ដឹកនាំព្រឹទ្ធសភា សមាជិក សមាជិកា គណៈកម្មការទាំង១០ និងក្រុមនានារបស់ព្រឹទ្ធសភា អញ្ជើញចុះបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ព្រមទាំងក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន២,៣៦៥លើក។
- បានសម្រួលដំណើរការបញ្ជូនឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល តាមរបប២ឆ្នាំ ចប់អាណត្តិ ឬលាឈប់ និងទទួលការតែងតាំងថ្មី ទៅអង្គភាពប្រឆាំងអំពើពុករលួយ ចំនួន២១២នាក់។

**៤.៤-ការងារស្រាវជ្រាវ៖**

- បានសិក្សាស្រាវជ្រាវ និងរៀបចំឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ ចំនួន២៨ច្បាប់។
- បានសិក្សាស្រាវជ្រាវ រៀបចំឯកសារ និងធ្វើបទបង្ហាញជូនសមាជិក សមាជិកាព្រឹទ្ធសភា លើសេចក្តីព្រាងច្បាប់ និងប្រធានបទនានា ចំនួន៣២ច្បាប់។
- បានតាមដានអំពី៖

• ការអនុវត្តច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥ និងការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ និង
• ដំណើរការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦។

- បានសិក្សាស្រាវជ្រាវ និងតាមដានវឌ្ឍនភាពនៃការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយពាក់ព័ន្ធតាមវិស័យនានា។
- បានសង្ខេប "យុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា" និង "លទ្ធផលប្រមូលចំណូលពន្ធក្នុងស្រុក ប្រចាំត្រីមាសទី៤ ឆ្នាំ២០២៤ និងត្រីមាសទី១ ឆ្នាំ២០២៥"។
- បានបញ្ចូលទិន្នន័យ ព័ត៌មាន និងចាត់ថ្នាក់ទៅតាមវិស័យច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ក្នុងប្រព័ន្ធមូលទិន្នន័យ ចំនួន១,៦៨៩ច្បាប់។
- បានបកប្រែ និងសង្ខេបព័ត៌មានសភាបញ្ចូលក្នុងសម្រង់សង្ខេបព័ត៌មានសំខាន់ៗប្រចាំថ្ងៃ ចំនួន១,៤២៦ព័ត៌មាន និង
- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច ប្រចាំសប្តាហ៍ ក្នុងឆមាសទី១ ឆ្នាំ២០២៥ ចំនួន១៦ច្បាប់។

**៤.៤-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖**

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា ចំនួន១០១លើក។
- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងបណ្តាញសង្គម ចំនួន៨,៨៩៣លើក។
- បានបញ្ចូលព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភា ចំនួន២,១៨៤សកម្មភាព។
- បានអញ្ជើញអ្នកសារព័ត៌មាន ចូលយកព័ត៌មានព្រឹទ្ធសភា និងពិធីផ្សេងៗ ចំនួន៥៣លើក។
- បានប្រមូល និងផ្សព្វផ្សាយព័ត៌មានក្នុងឆានែលតេឡេក្រាម ព័ត៌មានប្រចាំថ្ងៃព្រឹទ្ធសភា ចំនួន៥,៧៦១ប្រធានបទ។
- បានតាំងពិព័រណ៍រូបភាពសកម្មភាពរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភានៅខ្លោងទ្វារខាងមុខព្រឹទ្ធសភា ចំនួន៧២លើក។
- បានរៀបចំផលិតទស្សនាវដ្តីព្រឹទ្ធសភា ប្រចាំខែមករា-ខែមិថុនា ឆ្នាំ២០២៥។
- បានសិក្សាស្រាវជ្រាវ ចងក្រងព្រឹត្តិបត្រស្តីពី បច្ចេកវិទ្យាព័ត៌មាន ចំនួន៣១២ចំណងជើង។
- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធណេតវើក អ៊ីនធឺណែត ពង្រឹងពង្រីកការផ្គត់ផ្គង់ ថែទាំ និងជួសជុលឧបករណ៍ សម្ភារៈ បរិក្ខារបច្ចេកទេស ព្រមទាំងដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មាន ចំនួន៣៤៧គ្រឿង/លើក។

- បានរៀបចំប្រព័ន្ធសូឌីយ៉ូ ប្រព័ន្ធកាមេរ៉ា ប្រព័ន្ធប្រជុំនិម្មិត ព្រមទាំងបានរចនាផ្ទាំង Backdrop Background និងបញ្ចាំងផ្ទាំង LED ក្នុងកិច្ចប្រជុំ ជំនួបសម្ដែងការគួរសម និងពិភាក្សាការងារជាមួយភ្ញៀវជាតិ-អន្តរជាតិ និងកម្មវិធីផ្សេងៗ ចំនួន២១៣លើក។
- បានទទួលឯកសារ សៀវភៅច្បាប់ ទស្សនាវដ្តី ព្រឹត្តិបត្រ និងសៀវភៅជំនាញផ្សេងៗ ចំនួន ៧៨ក្បាល ព្រមទាំងបានចុះបញ្ជីសៀវភៅ ដាក់លេខកូដសៀវភៅ បោះត្រាបិទប័ណ្ណខ្ចី និងសងសៀវភៅ ចំនួន១២១ក្បាល។
- បានផ្សព្វផ្សាយឯកសាររបស់ព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឯកសារច្បាប់ ឯកសារជំនាញផ្សេងៗ និងសៀវភៅជា E-Book តាមគេហទំព័រ www.elibrary.senate.gov.kh ចំនួន ៧,៦៧២ក្បាល ដែលមានសាធារណជនចូលអាន ចំនួន១,០២៧នាក់ (ដោយគិតត្រឹមខែមិថុនា ឆ្នាំ២០២៥) និង
- បានទទួលឯកសារពីអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងបានរៀបចំចាត់ចែងតម្កល់រក្សាទុកឯកសារនៅបណ្ណសារដ្ឋាន ដោយបានរៀបចំសៀវភៅព្រឹត្តិបត្រព្រឹទ្ធសភា(ស្ទួន) ឆ្នាំ២០១១-២០១៣ ចំនួន៤,៩៩៥ក្បាល ត្រួតពិនិត្យបញ្ចូលមាតិកាលិខិត និងមាតិកាសំណុំលិខិតទៅក្នុងប្រព័ន្ធកុំព្យូទ័រ ចំនួន២៩៥សំណុំ។

**៤.៦-ការងារពិធីការ និងទំនាក់ទំនងអន្តរជាតិ៖**

- បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ ជំនួបសម្ដែងការគួរសម ពិភាក្សាការងារ និងពិធីផ្សេងៗ ចំនួន១៦១លើក។
- បានបកប្រែឯកសារ រៀបចំលិខិតឆ្លើយតបជាភាសាអង់គ្លេស រៀបចំឯកសារជំនួយស្មារតី រៀបចំកំណត់បង្ហាញ និងឯកសារផ្សេងៗ ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៤៦ច្បាប់/លើក។
- បានរៀបចំបែបបទស្នើសុំលិខិតឆ្លងដែនការទូត និងផ្លូវការជូនសមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំ មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងក្រុមគ្រួសារ ចំនួន១៤រូប។
- បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិ ប្រចាំខែមករា-ខែមិថុនា ឆ្នាំ២០២៥ ចំនួន៦ច្បាប់។
- បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំនួន៣២ច្បាប់ និង
- បានតុបតែងលម្អបំភ្លឺភ្លើងពណ៌នៅខាងមុខស្ថាប័នព្រឹទ្ធសភា និងចងបដា ពាក្យស្លោក ដាក់តាំងប៉ាណូ ក្នុងឱកាសនៃព្រះរាជពិធីជាតិ និងពិធីបុណ្យជាតិ-អន្តរជាតិ ចំនួន៨លើក។

**៤.៧-ការងារអគ្គាធិការដ្ឋាន៖**

- បានប្រជុំពិភាក្សាការងារអំពីលទ្ធផលការងារសង្គមកិច្ច និងការផ្តល់សេវាជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំឆមាសទី១ ឆ្នាំ២០២៥ ចំនួន១៣២លើក។

- បានប្រមូល និងរៀបចំរបាយការណ៍ជាមួយនាយកដ្ឋានផែនការ និងសរុប នាយកដ្ឋានគ្រប់គ្រងបុគ្គលិក នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស និងបណ្ណសារដ្ឋានស្តីពី ការអនុវត្តផែនការការងារ និងគោលនយោបាយនានា របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានរៀបចំរបាយការណ៍ស្តីពី លទ្ធផលការងាររបស់នាយកដ្ឋានត្រួតពិនិត្យការងារសង្គមកិច្ច និងការផ្តល់សេវា ប្រចាំខែមករា-ខែមិថុនា និងប្រចាំឆមាសទី១ ឆ្នាំ២០២៥ ចំនួន៧លើក។
- បានចុះត្រួតពិនិត្យវត្តមានជាក់ស្តែងតាមនាយកដ្ឋាននានា ប្រចាំឆមាសទី១ ឆ្នាំ២០២៥ ចំនួន ១២លើក ដើម្បីផ្ទៀងផ្ទាត់បញ្ជីវត្តមាន ដែលនាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ។
- បានបូកសរុប និងធ្វើរបាយការណ៍សម្រង់វត្តមានប្រចាំថ្ងៃ ចំនួន២៤០លើក ប្រចាំសប្តាហ៍ ចំនួន ២៤លើក ប្រចាំខែមករា-ខែមិថុនា និងប្រចាំឆមាសទី១ ឆ្នាំ២០២៥ ចំនួន៧លើក ដែលគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ។
- បានចុះត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពី បរិស្ថាន អនាម័យ ការខូចខាតសម្ភារៈតាមអគារ និងសណ្តាប់ធ្នាប់នៃការចតយានយន្តក្នុងបរិវេណព្រឹទ្ធសភា និង
- បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីរាជការតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## II-ទិសដៅការងារឆមាសទី២ ឆ្នាំ២០២៥

### ១- មុខងារនីតិកម្ម

- ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ប្រជុំពេញអង្គព្រឹទ្ធសភា និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ និង
- ត្រៀមប្រជុំផែនការថវិការបស់ព្រឹទ្ធសភា ឆ្នាំ២០២៦ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ត្រៀមបែបបទ និងនីតិវិធីក្នុងការបម្រើសេវាជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំព្រឹទ្ធសភាពាក់ព័ន្ធនឹងសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

### ២-មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយក្រសួង ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ និងចុះបេសកកម្ម ដើម្បីតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។
- ទ្រទ្រង់ដំណើរឆ្ពោះទៅកាន់មូលដ្ឋានរបស់សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងរយៈពេលវិស្សមកាលចាប់ពីថ្ងៃទី៧ ខែកក្កដា ដល់ថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៥ និង
- បង្កើនគុណភាព និងប្រសិទ្ធភាពផ្តល់សេវាជូនសមាជិក សមាជិកាព្រឹទ្ធសភា ឱ្យបានល្អប្រសើរ និងគ្រប់ជ្រុងជ្រោយក្នុងដំណើរចុះមូលដ្ឋាន និងជួបពិភាក្សាការងារជាមួយក្រសួង ស្ថាប័ននានា។

### ៣- មុខងារតំណាង

- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល

សាកសួរសុខទុក្ខប្រជាពលរដ្ឋ ពិភាក្សាការងារជាមួយអាជ្ញាធរដែនដី ពិនិត្យវឌ្ឍនភាពនៃការអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ ចូលរួមសិក្ខាសាលា វេទិកា កិច្ចប្រជុំនានា និងពិធីផ្លូវការផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។

- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចូលរួមពិធីបុណ្យប្រពៃណីសាសនា បុណ្យប្រពៃណីជាតិ និងបុណ្យជាតិ-អន្តរជាតិនានា។
- ត្រៀមរៀបចំទិវាមនុស្សចាស់ ឆ្នាំ២០២៥។
- ត្រៀមទទួលដំណើរទស្សនកិច្ចរបស់សាធារណជន សិស្ស និស្សិតមកកាន់ព្រឹទ្ធសភា។
- ត្រៀមរៀបចំសារលិខិតជូនពរ លិខិតអបអរសាទរ លិខិតថ្លែងអំណរគុណ លិខិតរំលែកទុក្ខរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាជូនឥស្សរជនជាន់ខ្ពស់ជាតិ-អន្តរជាតិ និងថ្នាក់ដឹកនាំតាមក្រសួង ស្ថាប័ននានា និង
- បន្តទទួលពាក្យបណ្តឹង និងសហការជាមួយក្រសួង ស្ថាប័ន មានសមត្ថកិច្ច ដើម្បីដោះស្រាយបណ្តឹងជូនប្រជាពលរដ្ឋ។

## ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

- ត្រៀមរៀបចំជំនួបជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ជាមួយឥស្សរជនជាន់ខ្ពស់បរទេស និងអង្គទូតនានានៃបណ្តាប្រទេសជាមិត្ត។
- ត្រៀមលក្ខណៈរៀបចំដំណើរទស្សនកិច្ចរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញទស្សនកិច្ចផ្លូវការ ចូលរួមកិច្ចប្រជុំ វេទិកា សិក្ខាសាលា និងកម្មវិធីផ្សេងៗ នៅក្រៅប្រទេស។
- ត្រៀមផ្តល់សេវាចាំបាច់បម្រើការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកានានា កម្មវិធីជំនួប កម្មវិធីផ្លូវការ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូនានា។
- បន្តត្រៀមស្រាវជ្រាវ បកប្រែ និងរៀបចំឯកសារជំនួយស្មារតី សុន្ទរកថាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបជាមួយភ្ញៀវអន្តរជាតិក្នុងជំនួបសវនាការ កិច្ចប្រជុំ និងទស្សនកិច្ចនានា និង
- បន្តសហការជាមួយដៃគូសំខាន់ៗ អនុវត្តកម្មវិធីសហប្រតិបត្តិការ និងបន្តស្វែងរកជំនួយសម្រាប់អភិវឌ្ឍន៍ស្ថាប័ន ធនធានមនុស្ស និងបច្ចេកវិទ្យាព័ត៌មាន។

## ៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន

- ត្រៀមសហការរៀបចំរបាយការណ៍ស្តីពី សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី៣ និងលើកទី៤ នីតិកាលទី៥ ឱ្យបានល្អ និងទាន់ពេលវេលា។
- ត្រៀមរៀបចំរបាយការណ៍ទូទាត់ថវិកាព្រឹទ្ធសភា ប្រចាំឆ្នាំ២០២៥ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា។
- ត្រៀមការពារគម្រោងថវិកាឆ្នាំ២០២៦ របស់ព្រឹទ្ធសភា ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ត្រៀមបែងចែកកញ្ចប់ថវិកាឆ្នាំ២០២៦ សម្រាប់រចនាសម្ព័ន្ធនយោបាយ និងរចនាសម្ព័ន្ធរដ្ឋបាល។

- បន្តធ្វើផែនការបណ្តុះបណ្តាល និងការអភិវឌ្ឍធនធានមនុស្សរយៈពេល៥ឆ្នាំ (ឆ្នាំ២០២៥-២០៣០) របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បន្តអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានារួមមាន ការសាងសង់អគារថ្មី ការជួសជុល ថែទាំ កែលម្អបរិស្ថាន អនាម័យ សួនច្បារ ប្រព័ន្ធអគ្គិសនី ប្រព័ន្ធទឹក ប្រព័ន្ធលូ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងប្រព័ន្ធសន្តិសុខ ផ្ទៃក្នុងព្រឹទ្ធសភា ប្រកបដោយសុខសុវត្ថិភាព។
- បន្តសិក្សាចងក្រងសៀវភៅស្តីពីប្រវត្តិនៃស្ថាបត្យកម្មរបស់ព្រឹទ្ធសភា ចាប់តាំងពីនីតិកាលទី១ រហូតដល់នីតិកាលទី៥ ព្រឹទ្ធសភា រួមជាមួយស្ថាបត្យកម្មថ្មីជាប្រវត្តិសាស្ត្រ ដែលកំពុងសាងសង់ជិតរួចរាល់ផងដែរ សម្រាប់អ្នកជំនាន់ក្រោយបានសិក្សាឈ្វេងយល់។
- ត្រៀមរៀបចំពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារថ្មី ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា។
- ត្រៀមរៀបចំទទួលគម្រោងអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មានសម្រាប់ព្រឹទ្ធសភា ក្រោមក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណងពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន។
- ត្រៀមជួសជុលកែលម្អសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា ដែលមានសភាពចាស់ទ្រុឌទ្រោម ដើម្បីឱ្យមានសោភណភាព ដោយធានារក្សានូវទម្រង់ និងស្ថានភាពដើម។
- បន្តផ្តល់សេវាផ្គត់ផ្គង់សម្ភារៈ ថវិកា មធ្យោបាយដឹកជញ្ជូន ទំនាក់ទំនងជាមួយអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងសេវាសំខាន់ៗផ្សេងទៀតជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងាររបស់ខ្លួនឱ្យបានទាន់ពេលវេលា និងល្អប្រសើរ។
- បន្តចុះសួរសុខទុក្ខមន្ត្រីរាជការលំហែមាតុភាព និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- ត្រៀមរៀបចំផលិត និងផ្សព្វផ្សាយ៖
  - ខ្សែវីដេអូព័ត៌មានរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
  - ទស្សនាវដ្តីព្រឹទ្ធសភា ប្រចាំខែកក្កដា-ខែធ្នូ ឆ្នាំ២០២៥។
  - ប្រតិទិន និងសៀវភៅទិនានុលេខន៍ព្រឹទ្ធសភាឆ្នាំ២០២៦។
  - ប័ណ្ណរថយន្តចេញ-ចូល ក្នុងបរិវេណព្រឹទ្ធសភា ឆ្នាំ២០២៦ និង
  - ខិត្តប័ណ្ណបុណ្យជាតិ។
- បន្តរៀបចំបណ្ណសារដ្ឋានអេឡិចត្រូនិច និង
- បន្តពង្រឹងពង្រីកការងារសេវាគាំទ្រផ្នែកបច្ចេកវិទ្យាព័ត៌មានព្រឹទ្ធសភាឱ្យកាន់តែទំនើបប្រកបដោយគុណភាព និងប្រសិទ្ធភាព។

## III-សេចក្តីសន្និដ្ឋាន

ក្នុងឆមាសទី១ ឆ្នាំ២០២៥នេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអនុវត្តការងារសម្រេចបានលទ្ធផលកាន់តែល្អប្រសើរលើមុខងារទាំង៥ ធៀបនឹងឆមាសទី១ ឆ្នាំ២០២៤។ ស្ថិតក្នុងបរិការណ៍នៃកិច្ចការពារបូរណភាពទឹកដី ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

បានរួមចំណែកយ៉ាងសស្រាក់សស្រាំជាមួយរាជរដ្ឋាភិបាល ចុះសួរសុខទុក្ខ និងផ្តល់ការឧបត្ថម្ភ ជ្រោមជ្រែង ជូនកងទ័ពជួរមុខឈរជើងការពារតាមបណ្តោយខ្សែបន្ទាត់ព្រំដែន គ្រួសារកងទ័ព និង ប្រជាជន ក្នុងស្មារតីរួបរួមជាតិតែមួយ។ វឌ្ឍនភាពទាំងនេះ ជាសូចនាករនៃការគ្រប់គ្រង ដឹកនាំ និងការខិតខំរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្នុងការបំពេញការងារយកអស់កម្លាំងកាយ កម្លាំងចិត្ត ប្រាជ្ញាស្មារតី ប្រកបដោយបុរេសកម្ម នវានុវត្តន៍ លើគ្រប់ការដ្ឋានការងារ ស្របតាមផែនការយុទ្ធសាស្ត្រ ឆ្នាំ២០២១-២០៣០ សម្រាប់ការអភិវឌ្ឍស្ថាប័នព្រឹទ្ធសភា ឱ្យក្លាយជាសភាទំនើប។

លទ្ធផលសម្រេចបានក្នុងឆមាសទី១ ឆ្នាំ២០២៥ តម្រូវឱ្យខិតខំបន្ថែមទៀត ដើម្បីពង្រឹងពង្រីក ការងារលើគ្រប់វិស័យ និងគ្រប់មុខសញ្ញាឱ្យបោះជំហានទៅមុខព្រមៗគ្នា ហើយសម្រេចបានលទ្ធផល កាន់តែល្អប្រសើរបន្ថែមទៀត។

ថ្ងៃអង្គារ ៧កើត ខែ កត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៥

**អគ្គលេខាធិការ**

**ឡាយ សំកុល**